ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី១ ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ



ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

## គតិបណ្ឌិតបិតាស្ថាបនិកសន្តិភាពកម្ពុជា

« ជោគជ័យណាក៏ដោយ មិនត្រូវមើលរំលង កត្តាសន្តិភាពទេ ! »

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
ថ្ងៃទី២ កុម្ភៈ ២០២៣

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- យឹម ណុលសន

និពន្ធនាយក

- អ៊ីវ ចុង

ការិយាល័យនិពន្ធ

- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

អ្នកចាត់ចែងផលិត

- ប៉ិច សុខា
- អ៊ិន តុលា

អ្នកចែកផ្សាយ

- អៀង រដ្ឋា
- សេក វុទ្ធី

ការីកុំព្យូទ័រ

- អេង រត្នមុនី
- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

ទំព័រ


I- វិចារណកថា ដំណើរទេស្សនកិច្ច សម្ដេចតេជោ ហ៊ុន សែន ក្នុងយុគ្គសម័យ ស.វ. ទី២១ នៃទំនាក់ទំនងកម្ពុជា-ចិន បានផ្ដល់ផលប្រយោជន៍យ៉ាងធំធេង ១

II- បទអត្ថាធិប្បាយ សង្គ្រាម - ហេតុ និង ផលវិបាក ២-៤

III- ការពិនិត្យផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្ដីព្រាងផែនការជាតិទសវត្សរ៍សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០២១-២០៣០ ៥-៦

២- គោលនយោបាយជាតិស្ដីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ ៧-៨

IV- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០២២ ៩-១៥

V- បទវិភាគ៖

១- សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ផ្លាស់ប្ដូរពិភពលោកដូចខាងក្រោម ១៦-១៧

២- ប្រទេសរុស្ស៊ីឆ្លើយតបនឹងកញ្ចប់ទណ្ឌកម្មសេដ្ឋកិច្ច ខណៈដែលប្រទេសចិនបានច្រានចោលការសន្ទនាយោធាអាមេរិក-ចិន ១៨-១៩

VI- នាទីសិក្សា-ស្រាវជ្រាវ

- ការសិក្សាស្រាវជ្រាវសាគរសាស្ត្រ និងធនធានជលផលនៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣-១៩៨៦ (ត) ២០-៣០

VII- នាទីវប្បធម៌

១- ពន្យល់ពាក្យ ៣១

២- ស្វែងយល់ពី កវីនិពន្ធ កេង វ៉ាន់សាក់ ៣២-៣៣

VIII- នាទីកំណាព្យ

- កើតជាមនុស្សនេះ (កាកគតិ) ៣៤

- ទុក្ខសេកព្រាត់សារិកា (ពាក្យ៧) ៣៤

IX- នាទីកំសាន្ត

- ពិតជាថ្លើមពាសមេឃ! ៣៥

- អ្នកតាទឹក អ្នកតាភ្នំ (ទេវកថា) ៣៥

# ដំណើរទស្សនកិច្ច សម្តេចតេជោ ហ៊ុន សែន ក្នុងយុគ្គសម័យ ស.វ.ទី២១ នៃទំនាក់ទំនងកម្ពុជា-ចិន បានផ្តល់ផលប្រយោជន៍យ៉ាងធំធេង

*ដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា*

ស្ថិតក្នុងដំណើរទស្សនកិច្ចជាផ្លូវការរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅប្រទេសចិន កាលពីថ្ងៃទី៩-១១ ខែកុម្ភៈ ឆ្នាំ២០២៣ កន្លងមកនេះ បន្ទាប់ពីជំនួបពិភាក្សារវាងសម្តេចតេជោ និងលោក **ស៊ី ជីនពីង** ប្រធានាធិបតីចិន ប្រកបដោយភាពរួសរាយរាក់ទាក់និងស្និទ្ធស្នាលយ៉ាងកក់ក្តៅរួចមកគឺធ្វើឱ្យទំនាក់ទំនងរវាងកម្ពុជា-ចិនកាន់តែមានភាពរឹងមាំ និងផ្តល់នូវផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកថ្មីៗថែមទៀតយ៉ាងធំធេង ក្នុងបុព្វហេតុថៃរក្សា"សន្តិភាពនិងការអភិវឌ្ឍ"ក្នុងយុគ្គសម័យស.វ.ទី២១ នេះតរៀងទៅ។

នេះបានបង្ហាញថា ទំនាក់ទំនងការទូតរវាងសម្តេចតេជោ និងមហាយក្សចិន កាន់តែស៊ីជម្រៅដោយឈរលើផលប្រយោជន៍ទៅវិញទៅមក។

ស្ថិតក្នុងអត្ថន័យជាប្រវត្តិសាស្ត្រនេះ បើពិនិត្យមើលទៅលើផលប្រយោជន៍សម្រាប់ភាគីចិន គឺកម្ពុជា បានប្រកាសគោលនយោបាយការបទេសគាំទ្រចិន មានជាអាទ៍៖

ទី១: គោរពយ៉ាងខ្ជាប់ខ្ជួននូវនយោបាយ"ចិនតែមួយ" ដែលជាផលប្រយោជន៍នយោបាយចិនដ៏ធំធេង ។

ទី២: ប្រឆាំងការជ្រៀតជ្រែកពីខាងក្រៅ ចូលកិច្ចការផ្ទៃក្នុងរបស់ចិន ពីព្រោះថា កម្ពុជា គឺជាមាត់ច្រកទ្វារការទូតមួយយ៉ាងសំខាន់សម្រាប់ចិនទៅកាន់អាស៊ាន ក្នុងការធ្វើសមាហរណកម្មតំបន់ និងលំហូរទៅកាន់ពិភពលោក។

ទី៣: គាំទ្រចិនការពារផលប្រយោជន៍ស្នូលព្រមទាំងការបង្រួបបង្រួមជាតិ ពីព្រោះថា ក្នុងឋានៈកម្ពុជាជាសមាជិកនៃស្ថាប័នអន្តរជាតិ មានសារៈសំខាន់ណាស់ក្នុងកិច្ចប្រជុំថ្នាក់តំបន់ កិច្ចប្រជុំអាស៊ីបូព៌ា កិច្ចប្រជុំអាស៊ានបូក និងអង្គការសហប្រជាជាតិស្តីពីបញ្ហាសមុទ្រចិនខាងត្បូង។

ទន្ទឹមនឹងនេះបើងាកមកមើលផលប្រយោជន៍សម្រាប់កម្ពុជាវិញ គឺភាគីចិនបានប្រកាសគោលនយោបាយការបទេសគាំទ្រកម្ពុជាមានជាអាទ៍៖

ទី១: ការជ្រើសរើសមាគ៌ាអភិវឌ្ឍន៍ របស់កម្ពុជា ស្របតាមលក្ខខណ្ឌជាតិរបស់ខ្លួន។

ទី២: កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការការពារអធិបតេយ្យ សន្តិសុខ និងផលប្រយោជន៍អភិវឌ្ឍន៍។

ទី៣: ការអភិវឌ្ឍបន្តបន្ទាប់តាមរបៀបវារៈនយោបាយកម្ពុជា។

ទី៤: ប្រឆាំងដាច់ខាតចំពោះការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា។

ចំពោះវិស័យសេដ្ឋកិច្ចពាណិជ្ជកម្មនេះ ទៀតសោត ភាគីទាំងពីរបានឈានដល់កិច្ចសហប្រតិបត្តិការកម្រិតខ្ពស់ថ្មីមួយទៀត ហៅថា "ត្បូងពេជ្រ" សំដៅដល់សសរស្តម្ភ នយោបាយ ផលិតកម្មកសិកម្ម ថាមពល និងសន្តិសុខ ដែលជាគ្រឹះនៃអធិបតេយ្យជាតិ និងសេដ្ឋកិច្ចជាតិរបស់ប្រជាជាតិនីមួយៗ។

ហេតុនេះចំពោះទំនាក់ទំនងកម្ពុជា-ចិន ក្នុងយុគ្គសម័យស.វ.ទី២១នេះពិតជាទំនាក់ទំនងជាយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយជាដៃគូគាំទ្រគ្នាទៅវិញទៅមកនិងជាទំនាក់ទំនងសេដ្ឋកិច្ចពាណិជ្ជកម្មយ៉ាងស៊ីជម្រៅ។

ដូច្នេះបើនិយាយអំពីនយោបាយការបរទេសកម្ពុជា គឺប្រកាន់យក "ផ្កាចម្រុះពណ៌" បានន័យថាបណ្តាប្រទេសនានាលើពិភពលោក ជាមិត្តរបស់កម្ពុជា៕

# សង្គ្រាម - ហេតុ និង ផលវិបាក

សង្គ្រាមលោកលើកទី១ ឆ្នាំ១៩១៤-១៩១៨ បានផ្ដាច់ជីវិតមនុស្ស៨៧០០០០០នាក់ទាំងទាហានទាំងស៊ីវិល បានធ្វើឱ្យប្រទេសធំៗចាយលុយអស់ ៦៥០ ពាន់លានហ្វ្រង់ (ហ្វ្រង់ឆ្នាំ១៩១៤) បានបង្លិនទំនិញជិត ២០ លានតោន បានកម្ទេចនាវាចម្បាំងអស់ជិតមួយលានតោន(ប្រសិនបើគិតជាទម្ងន់)បានកម្ទេចនាវាមុជទឹកអាល្លឺម៉ង់អស់ជិត ៦០០ គ្រឿង ... បានបំផ្លាញផ្ទះសម្បែង ដីធ្លី ទីក្រុង ជនបទ ព្រមទាំងធ្វើឱ្យមនុស្សរបួសបាក់បែកយ៉ាងវេទនារាប់មិនអស់។

សង្គ្រាមលោកលើកទី២ ឆ្នាំ១៩៣៩-១៩៤៥ បានសម្លាប់មនុស្សអស់ ៣៨ លាននាក់ ហើយមានសភាពខ្លាំងសាហាវជាងលើកទី១ គួរឱ្យរន្ធត់ ដោយសារការអនុវត្តតិចនិចទំនើប។ ក្រៅពីទំនិញ កប៉ាល់ និងយន្តយានជើងគោកខ្ទេចខ្ទី គេឃើញមានយន្តហោះ ប្រហែល ដប់ម៉ឺន គ្រឿងត្រូវវិនាស ក្នុងបណ្ដាយន្តហោះប្រហែលហាសិបប្លាយម៉ឺនគ្រឿង ដែលគេបានសាង។ ប្រទេសជប៉ុនជាប់ឈ្មោះរន្ធឺជាងគេ ដោយសារគ្រាប់បែកបរមាណូពីរគ្រាប់ដែលអ្នកប្រាជ្ញទើបនឹងសម្រេចរូបរាងនោះ បានផ្ដាច់សង្ខារពលរដ្ឋក្រុង ហ៊ីរ៉ូស៊ីម៉ា (Hiroshima) អស់ ៧៨ ០០០ នាក់ និងក្រុងណាហ្គាសាគី (Nagasaki) អស់ ២៧ ០០០ នាក់។ ក្រៅពីនេះមានរបួស ៨៤ ០០០ នាក់ នៅហ៊ីរ៉ូស៊ីម៉ា ៤១ ០០០ នាក់ នៅណាហ្គាសាគី ហើយផ្ទះឆេះម៉ត់ជាងប្រាំមួយម៉ឺនខ្នង និងហិនហោចសម្បត្តិទ្រព្យយ៉ាងសម្បើមក្នុងមួយពព្រិចភ្នែក។នេះជាគ្រាប់បែកខ្សោចច្រើនយៗនៅឡើយ ។

អង្គការសហប្រជាជាតិ ទើបនឹងបានឃើញថាពីពេលនេះទៅបើមានប្រើអាវុធបរមាណូសង្គ្រាមមួយអាចរំលាយជីវិតទាំងរយលាន រហូតក្បែរៗពាន់លាន ហើយអរិយធម៌ជនជាតិខ្លះ នឹងត្រូវផុតពូជ។ ជាឧទាហរណ៍គ្រាប់បែកមួយកម្លាំងប្រហែលម្ភៃមេហ្គាតោន អាចសម្លាប់មនុស្សប្រហែល ៦ឬ៧ លាននាក់ក្នុងចំណោមមនុស្សប្រហែល ៨លាននាក់ នៃក្រុងមួយ។

ប្រសិនបើគ្មានការការពារពិសេស គ្រាប់បែកកម្លាំង ១០ មេហ្គាតោន ចំនួន ៤០០ គ្រាប់ ផ្លោងចូលសហរដ្ឋអាមេរិក អាចផ្ដាច់ព្រលឹងជនជាតិនេះ អស់ ១០០ លាននាក់ គឺពាក់កណ្ដាលយ៉ាងតិច ... ។

ពីដើម មនុស្សវាយតប់ ទាត់ធាក់គ្នា ដោយប្រើដំបង ប្រើកាំបិត ដាវ លំពែង ធ្នូ ស្នា តមកកាំភ្លើង គ្រាប់បែក យានគោក យានទឹក យានអាកាស កាំជ្រួចឆ្លងទ្វីបរហូតគ្រាប់បែកប្រល័យលោក។អ្នកប្រាជ្ញខ្លះប៉ាន់ចំនួនថាតាំងពីមានមនុស្សលើដីមកចម្បាំងរវាងមនុស្សនឹងមនុស្ស បានសម្លាប់ជីវិតមនុស្សអស់ប្រហែល ៣០០ លាន នាក់ ។

សីលវិទូ បណ្ឌិត និង សង្គមវិទូ ចាប់អារម្មណ៍ច្រើនណាស់ចំពោះរឿងនេះ ដើម្បីត្រដងឱ្យឃើញទោស ឬផលអាក្រក់ផ្សេងៗផង ដើម្បីរកឱ្យឃើញហេតុធំៗផង និងដើម្បីសាករៀបចំឱ្យមានសន្តិភាពជាស្ថាពរ។ ទ្រឹស្ដីផ្សេងគ្នាជាច្រើនត្រូវគេរកឃើញ។

អ្នកខ្លះ មាន បូស៊ុយអេ (Bossuet) ហ្សូសេហ្វ ដឺ ម៉ៃត្រ (Joseph de Maistre ) ម៉ូរ៉ាស (Maurras) វ៉ុន មូឡៃក៍ (Von Molike) ជាដើម យល់ថា ចម្បាំងជាអម្រែកដែលព្រះជាម្ចាស់ចែកឱ្យ ។ យ៉ាងនេះ ទើបតាំងអារ៉ែស ម៉ស៊ីទីតាតែស រ៉ាគង់ ... តាំងជំនឿបែបនេះ។ ដូចនេះ គឺគេចមិនផុតគ្រោះសាហាវ គឺមនុស្សមិនអាចរៀបចំសន្តិភាពបានព្រោះជារឿងដែលផុតធន្ទៈ ឬសមត្ថភាពមនុស្ស។ ប៉ុន្តែសាសនាបច្ចុប្បន្នភាគច្រើន បានបដិសេធគំនិតនេះ ហើយគាំទ្រឧត្តមគតិនៃសន្តិភាពសាកល ។

លោកប្លាតុង រួចមក លោកអាឡាំង ឃើញថាចម្បាំងកើតពីចិត្តជក់វីរវក់របស់មនុស្ស ពិសេសគឺកំហឹង ពីការស្អប់ខ្ពើមគ្នា ពីគំនិតអួតអាងមើលងាយគ្នា...។ប្រសិនបើចម្បាំងចេញពីចិត្តបែបនេះមែននោះ

ក៏ពិបាកចៀសដែរ ព្រោះកំហឹង គំនិតអួតអាង ទ្រឹស្ដស្នូរ ខ្មៅកខ្វក់ ... ប្រហែលដូចជា លក្ខណៈចិតថេរដ៏មាំមួយទៅហើយ នៃប្រភេទមនុស្ស។

អ្នកខ្លះ ពិសេសអ្នកប្រកាន់ពូជពណ៌ យល់ថាចម្បាំងជារឿងចាំបាច់ ឬជាការចំរាញ់ស្របលក្ខណៈធម្មជាតិដែលអនុញ្ញាតឱ្យអ្នកខ្លាំងៗរំលាយអ្នកខ្សោយៗចោលបាន។នេះជាទ្រឹស្ដីលោកនីត(Nitzshe)និងលោក ម៉ាល់ទុស (Malthus) ។ លោក រ៉ឺណង់ យល់ថាចម្បាំងជាផ្នែកមួយដែលនាំឱ្យចម្រើនពិសេសជារំពាត់មួយដែលហាមប្រជាជាតិមិនឱ្យដេកស្ងៀម។ តាមគំនិតនេះ វិទ្យាសាស្ត្ររីកចម្រើនដោយសារចម្បាំង ព្រោះចម្បាំងជំរុលអ្នក ស្រាវជ្រាវឱ្យបង្កើតអ្វីថ្មីៗ។ ជាឧទាហរណ៍ ថាមពល បរមាណូត្រូវគេសិក្សា «ដោយសារ» ចម្បាំងនេះ។ លោក ម៉ាល់ទុសដដែល យល់ថែមទៀតថា ចម្បាំងធ្វើឱ្យមានលំនឹងចំនួនបណ្ដាជន តាមការបង្ហូរជីវិតចោល ដែលនាំឱ្យលែងមានបញ្ហាខ្វះការងារធ្វើ ។ តាមទ្រឹស្ដីទាំងនេះឃើញថា មនុស្សដូចជាគ្មានផ្លូវ ឬគ្មានប្រយោជន៍នឹងគេចពីចម្បាំងផង។

ទស្សនវិទូ អាឡាំង (Alain) សរសេរថា៖ « គ្រប់អំណាច តែងតែស្រឡាញ់ចម្បាំង ខំរកចម្បាំង ប្រកាសចម្បាំង និងបន្លាយចម្បាំង ដើម្បីឱ្យអំណាចនៅគង់ចិតថេរ»។ទ្រឹស្ដីនេះទម្លាក់ការទទួលខុសត្រូវផ្សេងៗក្នុងចម្បាំងឱ្យទៅមេកើយទៅអ្នកគ្រប់គ្រងនិងទៅវរជននៃប្រវត្តិសាស្ត្រ ។ តាមគំនិតនេះ ដើម្បីលប់ចម្បាំង ត្រូវលប់អ្នកទទួលខុសត្រូវជំតែមួយគត់ចោលចេញ។ បានសេចក្ដីថា ត្រូវរស់ក្នុងសភាពប្រជាធិបតេយ្យ។ គំនិតនេះ ដូចគំនិតលោក កាន្ត (KANT) ក្នុងសៀវភៅគម្រោងសន្តិភាពស្ថាពររបស់លោក «មានតែសាធារណរដ្ឋទេ ដែលអាចសង់សន្តិភាពស្ថាពរបាន» ... គ្មានប្រជារាស្ត្រណាចង់ច្បាំង ដូចនេះជាភារៈប្រជារាស្ត្រ ដែលត្រូវធ្វើយ៉ាងណា កុំឱ្យធ្លាក់ក្នុងចម្បាំងរបស់មេកើយខ្លួន » ។

ទ្រឹស្ដីអន្តរជាតិនិយម យល់ថា ចម្បាំងកើតពីការមានប្រជាជាតិ។ ដូចនេះ ចង់លប់ចម្បាំង ត្រូវលប់ព្រំប្រទល់ដែនទាំងអស់។ទ្រឹស្ដីដដែលនេះអាចនិយាយបានផ្សេងទៀតថា « ចម្បាំងកើតពីមានបក្សនយោបាយ » ឬ « ចម្បាំងកើតពីការមានទស្សនៈឧត្តមគតិផ្សេងគ្នា » ឬសព្វថ្ងៃនេះ « ចម្បាំងកើតពីការមានបក្សលោកកុំមុយនិស្ដ និង បក្សលោកសេរី » នេះឯង ។ តាមទ្រឹស្ដីនេះ ដើម្បីបានសន្តិភាព មានតែគេចកុំចូលខ្លួនជាពលរដ្ឋនៃជាតិៈបានសេចក្ដីថាបុគ្គលម្នាក់ៗ ក្លាយជាពលរដ្ឋនៃពិភពលោកតែម្ដង (citoyen du monde cosmopolisme ) ឬមានតែលប់ជាតិចោល ហើយនាំគ្នាទាំងពាន់លាននាក់ បង្កើតពិភពអន្តរជាតិឬមានតែបង្កើតច្បាប់ពលរដ្ឋអន្តរជាតិ ដូចជា អង្គការអាជ្ញាកណ្ដាល ឬការប្រកាសសិទ្ធិមនុស្សសាកល ឬក៏បង្កើតការចរចាបែបទូត (សន្និសីទអន្តរជាតិ - ការប្ដូរគ្នាទៅវិញទៅមកជាអន្តរជាតិ ស្ថាប័នអន្តរជាតិ)។ សព្វថ្ងៃទំនាក់ទំនងបែបជួយគ្នា បែបសហប្រតិបត្តិការបែបរួមរស់ក្នុងសន្តិភាពនិងបែបសាមគ្គីភាព កំពុងចាប់ផ្ដើមមានបន្តិចម្ដងៗ រវាងជាតិនានាហើយដូចគ្នានេះរវាងប្រព័ន្ធសេដ្ឋកិច្ចនានា នយោបាយនានា និងមនោគមនានានៃពិភពលោកបច្ចុប្បន្ន។គំនិតរំលាយអាវុធចោល(ផ្ទុយពីទ្រឹស្ដីបុរាណដែលថា ចង់បានសន្តិភាព ត្រូវរៀបចំចម្បាំងនោះ) ជាផ្នែកធំមួយនៃដំណើរការដ៏ទូលំទូលាយ របស់ពិភពលោកទំនើបនេះ។

ទ្រឹស្ដីមួយទៀតយល់ថា ចម្បាំងកើតពីបញ្ហាសេដ្ឋកិច្ច។ គឺជាទ្រឹស្ដីលោក ម៉ាក្ស (Marx) និងលោកហ្សែរ៉េស(Zorès)ដែលចែកចម្បាំងជាចម្បាំងខ្ញុំកញ្ជះចម្បាំងសក្តិភូមិ ចម្បាំងពាណិជ្ជកម្ម ចម្បាំងអាណានិគមចម្បាំងចក្រពត្តិចម្បាំងសង្កត់សង្កិននិងចម្បាំងរើបម្រះ។ទ្រឹស្ដីនេះភ្ជាប់ចម្បាំងទាំងឡាយទៅនឹងរឿងសេដ្ឋកិច្ច រឿងសង្គមកិច្ច រឿងនយោបាយ រឿងទស្សនៈ ហើយឃើញថា គ្រប់ចម្បាំងជាការបន្តនយោបាយ តាមមធ្យោបាយផ្សេងប៉ុណ្ណោះ(នយោបាយ ជានយោបាយរបស់ថ្នាក់មនុស្សណាមួយជានិច្ច)។ តាមគំនិតនេះ ដើម្បីបានសន្តិភាព មានតែថ្នាក់នីមួយៗ រួតប្រយុទ្ធគ្នាឱ្យឆាប់ចប់ នៅគ្រប់កន្លែងណា ដែលការប្រយុទ្ធអាចធ្វើបាន ដោយកុំជឿឬយល់ថារបៀបសង្គមនិយម និងមូលធននិយម អាច

ទល់មុខទស្សនៈផ្សេងៗ នៃចម្បាំងនេះ។ ជាការសន្និដ្ឋានគួរកត់សម្គាល់ថា ក្នុងសម័យយើង ពិភពលោកមានការសាមគ្គីថ្មីមួយ ប្រឆាំងគ្រោះថ្នាក់ដែលស្ទើរតែសាកលទៅហើយ នៃអាវុធបរមាណូ។ សាមគ្គីនេះមានប្រៀបលើទំនាស់តូចធំទាំងអស់រវាងប្រជាជាតិ រវាងបក្ខ ឬ ប្រព័ន្ធសេដ្ឋកិច្ច។ ក្រៅពីនេះ ជំនឿលើភាពសាហាវគេចមិនផុតនៃចម្បាំង បានរលប់បន្តិចម្ដងៗ ដោយសារគម្រោងការដ៏សំបូរហូរហៀរដើម្បីយល់និងក្ដោបបាតុភូតដ៏សោកសៅនេះ។

ព្រមគ្នានេះអ្នកប្រាជ្ញទាំងឡាយចេះតែសង្ឃឹមជានិច្ច តែចម្បាំងក៏បាចសាចពីទ្វីបមួយទៅ ទ្វីបមួយពីស្រុកទេសមួយ ទៅស្រុកទេសមួយ ជានិច្ចដែរ។ ក្រោយចម្បាំងលោកលើកទី២មកច្រើនដងហើយដែលឮថាអង្គការសហប្រជាជាតិឃាត់មិនឱ្យផ្ទុះចម្បាំងគួរឱ្យរន្ធត់ បានប្រព្រឹត្តទៅ នៅអាហ្វ្រិក អាស៊ី អារ៉ាប់ ប៉ាគិស្ថាន ចិន ឥណ្ឌា រុស្ស៊ី ពិសេស នៅវៀតណាមនិងលាវ។ ការបាត់ជីវិតដ៏មានតម្លៃពីផែនភព ចេះតែប្រព្រឹត្តទៅរាល់ថ្ងៃ ដោយទោះមានសន្និសីទ ឬការប្រឹងប្រែងដោះស្រាយរបស់អង្គការពិភពលោកធំៗគ្មានឈប់ឈរយ៉ាងណាក្ដី ក៏គេនៅតែមិនទាន់ដឹងប្រាកដបានថា ចប់អង្កាល់ ... ។

ហើយនៅចុងខែមីនា ឆ្នាំ១៩៧០ ជាវេនប្រទេសខ្មែរ ។ ចាស់ៗខ្លះគិតថា « អើជួបទៀតហើយទើបនឹងស្ងាត់មិនដល់ម្ភៃឆ្នាំផង»។ ខ្ញុំដែលតាំងពីកើតមកមិនដែលឃើញនឹងភ្នែកនោះបានដឹងត្រឹមតាមសៀវភៅថា ចម្បាំងជារឿងរបស់មនុស្សគ្រប់គ្នា។ ខ្ញុំនឹកឃើញច្បាប់ទូន្មានផ្សេងៗមានច្បាប់អរិយសត្ថាឬស្រីហិតោបទេស ក្នុងកម្មវិធីថ្នាក់ទី៣ ជាដើម ដែលចែងថា៖ « ពេលមានជំងឺ ថ្កើងឯគ្រូពេទ្យ ពេលកើតរឿងហេតុ ថ្កើងឯមន្ត្រី ពេលកលយុគភ័យ ថ្កើងឯទាហាន ... »។

ខ្ញុំចេះតែតក់ស្លុតរន្ធត់កាលណាឃើញឈាម។ ខ្ញុំចេះតែស្លុតរន្ធត់ កាលណាឃើញអាវុធផ្សេងៗ។ កុំបាច់ដល់កាំភ្លើងតូចធំ កុំបាច់ដល់កាំបិតសៀត ឬកាំបិតធម្មតាសូម្បីឃើញដំបងក៏គេញ័រញាក់ដែរ។ខ្ញុំតែងនិយាយប្រាប់អ្នកដែលធ្លាប់រៀនជាមួយគ្នាថា៖ « ខ្ញុំមិនដែលឃើញមនុស្សចាក់កមនុស្សទេ...ខ្ញុំមិនដែលឃើញមនុស្សវះពោះមនុស្ស ឬស៊ីថ្លើមមនុស្សទេ ... តែនៅពីតូចកាលណាខ្ញុំឮចាស់ៗនិយាយរឿងនេះខ្ញុំរន្ធត់ស្ទើរលោះព្រលឹង ខ្ញុំចេះតែស្ដាយជីវិត... សូម្បីឃើញចាមចាក់កគោឬចិនចាក់កជ្រូកម្ដងៗក៏ខ្ញុំរន្ធត់អស់ខ្លួនប្រាណដែរ » ។ មិត្តភក្តិ ឬគ្រូខ្លះឃើញថាខ្ញុំជាមនុស្សបែបធម៌អាថ៌ ...។

ខ្ញុំតែងសាករកផ្លូវចេញមួយឱ្យបានឆាប់ចប់ដែរ ប៉ុន្តែដូចជាមិនប្រាកដក្នុងខ្លួន ព្រោះចំណេះខ្ញុំពេក។ ម្យ៉ាងទៀតលាតត្រដាងទៅក៏ប្រហែលពិភពលោកមិនស្ដាប់ដែរ ព្រោះសូម្បីទស្សនវិទូ ហ្សង់ ប៉ូល សាត្រ ( Jean Paul Satre ) ដែលបានរង្វាន់ណូបែលដ៏ធំ ឬ ប៉ែរត្រង់ រ៉ូសែល ដែលគេទទួលជីវិតមួយស្គាល់ថា ជាមហាមនុស្សទៅហើយ ( បានរង្វាន់ណូបែលឆ្នាំ ១៩៥០ ) ក៏រកច្រកចេញមិនរួចភ្លាម គឺគំនិតលោក នៅត្រូវតែត្រឹមរង្វង់ទ្រឹស្តី ដែលរសាត់អណ្តែតមិនដឹងដល់ណាប៉ុណ្ណោះ ។ តើត្រូវធ្វើយ៉ាងម៉េច ?

មួយថ្ងៃៗហូរមកដល់ហូរហែដោយបង្កើតព្រឹត្តិការណ៍ថ្មីប្លែកមិនតិច ភាពភ័យអរមិនតិច ភាពសើចយំមិនតិច ហើយជីវិតមួយៗ ខំបន់ ខំដោះស្រាយ ខំគេចខំការពារ ខំធ្វើយ៉ាងណាឱ្យគង់វង់ និងជួបទុក្ខតិចបំផុតតាមអាច តាមកម្លាំងខ្លួន និងតាមកម្លាំងក្រៅខ្លួន ដូចជាពឹងសំណាងបុណ្យបាបជាតិមុន កន្សែងយ័ន្ត ទឹកមន្ត ឬសាច់សារលោហិតជាដើម។ មន្ត្រីនិងអ្នកមានធនធានធូរធារឬគួរៗនៅតាមស្រុកខេត្តនានាបានរត់មកភ្នំពេញច្រើនឡើងៗ ហើយតែងស្ដាប់ដំណឹងសុខទុក្ខ ជួបជុំឬព្រាត់ប្រាស ពីអ្នកដែលមកមិនរួចរៀងរាល់ពេល។ អ្នកខ្លះបង្អាប់គ្នាថា អីក៏ភ័យម្ល៉េះ ។ ប៉ុន្តែជីវិតបញ្ហាធំមួយគឺភ័យនេះឯង ។ តើនរណាដែលអះអាងបានថាខ្លួនមិនភ័យ...ភ័យខ្លាចស្លាប់ខ្លាចរបួសខ្លាចជួបគ្រោះកាចខ្លាចអត់បាយទឹក ខ្លាចព្រាត់គ្រួសារ ខ្លាចឈឺចុកចាប់ ខ្លាចបាត់បង់អ្វីដែលខ្លួនស្រឡាញ់ ... ខ្លាចទាំងអស់ ។ យ៉ាងនេះទើបដូនតាយើងតែងទូន្មានកូនចៅកុំឱ្យបំភ័យគ្នា : សូវកាប់កុំជ្រលរ ...៕

**ក្រមសីលធម៌ និង គុណធម៌ នៃការរស់នៅ**
**បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង**

## ១- សេចក្តីព្រាងផែនការជាតិទសវត្សរ៍សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០២១-២០៣០

កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ឯកឧត្តម **សួន លាងហៃ** និងឯកឧត្តម **ថេង ស៊ីធឿន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលដឹកនាំដោយ ឯកឧត្តម **កែន សត្ថា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងពិភាក្សាសេចក្តីព្រាងផែនការជាតិទសវត្សរ៍សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០២១-២០៣០។

ផែនការជាតិទសវត្សរ៍សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកនេះ ជាផែនការសកម្មភាពរយៈពេល១០ឆ្នាំ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ ជាផែនការជាតិទសវត្សរ៍សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី២ បន្តពីលើកទី១ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០២០ ដែលបានអនុវត្តរួចកន្លងមក។ ផែនការជាតិនេះគឺជាឧបករណ៍រួមចំណែកសម្រេចឱ្យបានជោគជ័យនូវការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ស្របតាមគោលនយោបាយជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤។ ផែនការនេះក៏បានសម្របសម្រួលផងដែរតាមផែនការសកម្មភាពសកលរបស់អង្គការសហប្រជាជាតិ ផ្អែកតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ស្របតាមការអភិវឌ្ឍជឿនលឿនរបស់ជាតិលើគ្រប់វិស័យនិងការវិវត្តប្រែប្រួលនៃវិស័យពាក់ព័ន្ធនឹងសកម្មភាពចរាចរណ៍ផ្លូវគោកជាច្រើនទៀត ដូចជា កំណើនប្រជាជន កំណើនសេដ្ឋកិច្ច កំណើនយានយន្ត កំណើនផ្លូវថ្នល់។ ជារួមផែនការជាតិទសវត្សរ៍សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី២នេះគឺជាផែនទីបង្ហាញផ្លូវដ៏សំខាន់លើកិច្ចការទប់ស្កាត់ និងកាត់បន្ថយអ្នកស្លាប់ និងរបួសដោយគ្រោះថ្នាក់ចរាចរណ៍តាមគោលដៅកំណត់។

សេចក្តីព្រាងផែនការជាតិនេះ ត្រូវបានចាប់ផ្តើមកសាងឡើងតាំងពីឆ្នាំ២០១៩ដោយក្រុមការងារជំនាញចម្រុះរបស់ក្រសួងមហាផ្ទៃ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសុខាភិបាល តាមលិខិតបង្គាប់ការ លេខ៣៤៦/១៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការ ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដោយបានសហការ សិក្សា ប្រមូលធាតុចូលពីគ្រប់ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងបានប្រជុំពិភាក្សាពិគ្រោះយោបល់ជាមួយមន្ត្រីជំនាញ ទីប្រឹក្សាជាតិអន្តរជាតិ និងថ្នាក់ដឹកនាំអគ្គ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក សរុបចំនួន៣០លើក ក្នុងនោះកិច្ចប្រជុំកម្រិតជំនាញបានធ្វើឡើងចំនួន២៤លើក សិក្ខាសាលាកម្រិតអន្តរជាតិប្រមូលធាតុចូល១លើក កិច្ចប្រជុំជាមួយទីប្រឹក្សាអន្តរជាតិ១លើក និងកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំចំនួន៤លើក។ មូលហេតុដែលនាំឱ្យកិច្ចការនេះប្រើប្រាស់ពេលវែង គឺដោយសារតែមានការចាំបាច់ត្រូវសិក្សាវាយតម្លៃលើផែនការជាតិទសវត្សរ៍សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី១ ធ្វើការវិភាគលើទិន្នន័យស្តីពីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោករយៈពេល១០ឆ្នាំ (២០១១-២០២០) កន្លងមក ព្យាករណ៍ចំនួនអ្នកស្លាប់រយៈពេល១០ឆ្នាំខាងមុខ (២០២១-២០៣០)និងសិក្សាការខាតបង់ដោយសារ

គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក។ កិច្ចការទាំងនេះមានការចូលរួមពី កម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ(UNDP)និងចាំបាច់ត្រូវឱ្យសមស្របតាមផែនការសកល ស្ដីពីទសវត្សរ៍សកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោក ២០២១-២០៣០ របស់អង្គការសុខភាពពិភពលោក ដែលទើបតែបានប្រកាសជាផ្លូវការ និងផ្សព្វផ្សាយជាសាធារណៈតាមប្រព័ន្ធវីដេអូពីចម្ងាយ (Online) កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១។

សេចក្ដីព្រាងផែនការជាតិទសវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោក ឆ្នាំ២០២១-២០៣០ នេះ មានគោលបំណងកាត់បន្ថយចំនួនអ្នកស្លាប់និងអ្នករបួសដោយសារគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកឱ្យបាន៥០% នៅឆ្នាំ២០៣០ ដោយផ្ដោតលើគោលដៅសំខាន់ចំនួន២គឺទី១.កាត់បន្ថយចំនួនអ្នកស្លាប់និងរបួសតាមកត្តាហានិភ័យ នៃគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក និងទី២.បង្កើនប្រសិទ្ធភាពការអនុវត្តការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកដោយផ្អែកតាមសសរស្ដម្ភចំនួន៦ នៃយុទ្ធសាស្ត្ររួម។

ដើម្បីសម្រេចនូវគោលបំណងខាងលើនេះ សេចក្ដីព្រាងផែនការជាតិ បានដាក់ចេញនូវយុទ្ធសាស្ត្ររបស់ខ្លួន ដោយបានកំណត់អនុវត្តលើគោលដៅជាក់លាក់គឺខេត្តដែលមានអត្រាខ្ពស់នៃចំនួនអ្នកស្លាប់និងចំនួនអ្នករបួស រួមមាន រាជធានីភ្នំពេញ និងខេត្តចំនួន១៤ គឺខេត្តកណ្ដាល ព្រះសីហនុ កំពង់ចាម សៀមរាប បន្ទាយមានជ័យ ក្រចេះ កំពង់ធំ បាត់ដំបង ពោធិ៍សាត់ ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ តាកែវ និងខេត្តកំពត។ យុទ្ធសាស្ត្រនេះត្រូវបានផ្ដោតលើមូលហេតុដែលបង្កឱ្យមានអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកខ្ពស់គឺការបើកបរលើសល្បឿនកំណត់ការមិនគោរពសិទ្ធិអាទិភាពការបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងការមិនពាក់មួកសុវត្ថិភាពការបើកបរមិនប្រកាន់ស្ដាំ ការវ៉ាជែង និងការបត់ក្នុងស្ថានភាពគ្រោះថ្នាក់ ការមិនគោរពសញ្ញាចរាចរណ៍ និងការប្រើប្រាស់ឧបករណ៍ទំនាក់ទំនងក្នុងពេលបើកបរ។ យុទ្ធសាស្ត្រនេះ មានសសរស្ដម្ភចំនួន៦ ដែលក្នុងនោះ សសរស្ដម្ភចំនួន៥ ស្របតាមផែនការសកម្មភាព សុវត្ថិភាពចរាចរណ៍ផ្លូវគោកសកល និងសសរស្ដម្ភចំនួន១ (សសរស្ដម្ភទី២) ស្របតាមស្ថានភាពជាក់ស្ដែង របស់ប្រទេសកម្ពុជា។ សសរស្ដម្ភទាំង៦នេះ រួមមាន ទី១.ពង្រឹងយន្តការគ្រប់គ្រងនិងដឹកនាំការងារសុវត្ថិ ភាពចរាចរណ៍ផ្លូវគោក ទី២.ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទី៣.ពង្រឹងការអប់រំផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ទី៤.ពង្រឹងការគ្រប់គ្រងវិស្វកម្មសុវត្ថិភាពផ្លូវថ្នល់ ទី៥.ពង្រឹងប្រសិទ្ធភាពនៃសេវាសង្គ្រោះបឋម និងសង្គ្រោះបន្ទាន់ និងទី៦.ពង្រឹងការគ្រប់គ្រងសុវត្ថិភាពយានយន្ត។

កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ បានឯកភាពលើខ្លឹមសារ និងទម្រង់នៃសេចក្ដីព្រាងផែនការជាតិនេះ និងបានកែសម្រួលពាក្យពេចន៍និងឃ្លាប្រយោគមួយចំនួនឱ្យបានត្រឹមត្រូវនិងមានសង្គតិភាព និងបានសម្រេចស្នើសុំមតិណែនាំដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីដាក់សេចក្ដីព្រាងផែនការជាតិទសវត្សរ៍សកម្មភាពសុវត្ថិចរាចរណ៍ផ្លូវគោក ឆ្នាំ២០២១-២០៣០ នេះឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី៕

*ដោយ សួង លាងហៃ (ក.ស.វ. - ក្រុម ១)*

# ២- គោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់លើការបង្កើនផលិតភាពតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ដោយយកចិត្តទុកដាក់លើវិស័យកសិកម្មជាវិស័យសំខាន់មួយក្នុងចំណោមវិស័យផ្សេងៗទៀតរួមចំណែកក្នុងកំណើនផលទុនជាតិនិងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ក្នុងកំលុងពេលនៃការរីករាលដាលនៃជម្ងឺកូវីដ១៩(២០២០-២០២១)វិស័យសេវាកម្មនិងឧស្សាហកម្មមានការធ្លាក់ចុះខណៈវិស័យកសិកម្មនៅតែរក្សាបានកំណើនវិជ្ជមានជាវិស័យមានសក្តានុពលនិងមានភាពធន់។

ដំណាំស្វាយចន្ទីគឺជាដំណាំកសិ-ឧស្សាហកម្មដែលប្រជាកសិករនិយមចូលចិត្តដាំដុះលើផ្ទៃដីប្រមាណ២៥៨៩៨៤ហិកតា(តួលេខឆ្នាំ២០២០) ហើយផ្ទៃដីប្រមូលផលចំនួន១៦៥៦៧ហិកតាទទួលបានបរិមាណផលសរុបប្រមាណ២៤២៤២៤តោន។ ផលិតផលស្វាយចន្ទីភាគច្រើនបាននាំចេញជាផលិតផលមិនទាន់កែច្នៃទៅកាន់ប្រទេសជិតខាងដែលនាំឱ្យបាត់បង់នូវតម្លៃបន្ថែមយ៉ាងច្រើន ដោយផលិតផលទាំងនោះត្រូវបានប្រទេសជិតខាងធ្វើការកែច្នៃនិងនាំចេញទៅប្រទេសដទៃទៀត។ គោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២០-២០២៧ បានរៀបចំឡើងដោយផ្អែកលើផែនការយុទ្ធសាស្ត្រដំណាក់កាលទី៤និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៩-២០២៣ ដោយផ្តោតលើការបង្កើនផលិតភាពនិងការប្រកួតប្រជែងតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ពិពិធកម្មដំណាំដែលមានសក្តានុពលមានឧត្តមភាពដណ្តើមភាពឈ្នះទីផ្សារក្នុងស្រុក ក្នុងតំបន់ និងពិភពលោក។

គោលនយោបាយជាតិស្តីពីស្វាយចន្ទី មានចក្ខុវិស័យអភិវឌ្ឍផលិតកម្ម ការកែច្នៃនិងទីផ្សារស្វាយចន្ទីឱ្យមានលក្ខណៈប្រកួតប្រជែងប្រកបដោយបរិយាបន្នធានានូវនិរន្តរភាពនិងការធ្វើពិពិធកម្មសេដ្ឋកិច្ច។ គោលបំណងនៃគោលនយោបាយនេះ គឺប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសផលិតនិងផ្គត់ផ្គង់ផលិតផលស្វាយចន្ទីដ៏សំខាន់មួយសម្រាប់បម្រើគ្រប់ទីកន្លែង នៃទីផ្សារ ដោយផ្តោតលើគោលដៅចម្បងចំនួនបី រួមមាន៖ ១.ការលើកកម្ពស់ទិន្នផល នៃការផលិត និងផលិតភាពប្រកបដោយគុណភាពប្រកួតប្រជែង ២.ការជំរុញការធ្វើឧស្សាហូបនីយកម្ម ដើម្បីបង្កើនតម្លៃបន្ថែមលើការប្រមូលផលនិងការកែច្នៃអនុផលស្វាយចន្ទីឱ្យសម្រេចបាន ២៥ភាគរយ នៅឆ្នាំ២០២៧ និង៥០ភាគរយនៅឆ្នាំ២០៣២ និង៣. ជំរុញការនាំចេញតាមរយៈការធ្វើពិពិធកម្មទីផ្សារការផ្សារភ្ជាប់អន្តរវិស័យក្នុងការនាំចេញកិច្ចសម្រួលពាណិជ្ជកម្មការកាត់បន្ថយចំណាយមិនចាំបាច់និងការលើកកម្ពស់ឧត្តមភាពដណ្តើមឈ្នះ។

អត្ថប្រយោជន៍នៃគោលនយោបាយនេះ គឺជាការបង្កើនផលិតភាព គុណភាព សុវត្ថិភាពស្វាយចន្ទីដោយការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មថ្មី អនុវត្តកសិកម្មល្អប្រើប្រាស់ពូជដំណាំមានគុណភាពខ្ពស់និងមានភាពធន់ប្រើប្រាស់ប្រព័ន្ធស្រោចស្រពមានប្រសិទ្ធិភាពខ្ពស់ បច្ចេកទេសក្រោយពេលប្រមូលផលល្អ។ អភិវឌ្ឍន៍កសិ-ឧស្សាហកម្មកែច្នៃ តាមរយៈការកៀងគរវិនិយោគក្នុងប្រទេសនិងក្រៅប្រទេសបង្កើនតម្លៃបន្ថែម។ អនុវត្តបច្ចេកទេសក្រោយពេលប្រមូលផលរួមមានការសំងួត ការបកសម្បក ការធ្វើចំណាត់ថ្នាក់ ការវិចខ្ចប់ ការកែច្នៃផលិតផលសម្រេចជាផលិតផលអាហារសម្រន់។អភិវឌ្ឍន៍ការកែច្នៃផ្សេងៗ

ដូចជាដំណាប់ស្វាយចន្ទី គេសជ្ជៈ ប្រេងស្វាយចន្ទី ទឹកដោះគោស្វាយចន្ទី។ល។ ជំរុញការនាំចេញផលិតផលស្វាយចន្ទីតាមរយៈការថែរក្សាទីផ្សារចាស់ ការចរចារបើកទីផ្សារគោលដៅថ្មី។ បញ្ហាប្រឈមរួមមាន ផលិតភាពទាប ថ្លៃដើមផលិតខ្ពស់ មិនទាន់ប្រើប្រាស់បច្ចេកទេសកសិកម្មមានប្រសិទ្ធិភាពនិងមានប្រសិទ្ធិផលក្នុងផលិតកម្ម។ ការកែច្នៃនៅមាន កំរិតត្រឹមលក្ខណៈសិប្បកម្ម កំរិតឧស្សាហកម្មមិនទាន់រីកចំរើនដោយការវិនិយោគមិនទាន់មានការទាក់ទាញ អ្នកនាំចេញចូលចិត្តទីផ្សារប្រទេសជិតខាងដោយការនាំចេញគ្រាប់ស្វាយចន្ទីទាំងសម្បក។

គោលនយោបាយជាតិស្ដីពីស្វាយចន្ទី ឆ្នាំ ២០២០-២០២៧ បានឆ្លងកិច្ចប្រជុំផ្ទៃក្នុងក្រុម២ នៃក.ស.វ. កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ ឆ្លងកិច្ចប្រជុំបច្ចេកទេសនៃទីស្ដីការគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២២ ដឹកនាំអង្គប្រជុំដោយសហប្រធាន ឯកឧត្តម **នរ៉ាណាឫទ្ធិ អាននន្ទយ៉ាត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអនុប្រធានក.ស.វ.ទទួលបន្ទុកក្រុម២ និងឯកឧត្តម **លី ច័ន្ទតុលា** អនុប្រធានក.ប.ច. តំណាងក្រសួងសាមីដោយឯកឧត្តម **រាជ រ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។ គោលនយោបាយនេះបានឆ្លងកិច្ចប្រជុំអន្តរក្រសួងនៃទីស្ដីការគណៈរដ្ឋមន្ត្រីថ្ងៃទី១៣ ទី៣១ ខែតុលា និងថ្ងៃទី៣ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលដឹកនាំអង្គប្រជុំដោយ ឯកឧត្តម **តឹករ៉ែត សំរេច** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជារដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី។

ជារួមគោលនយោបាយជាតិស្ដីពីស្វាយចន្ទីគឺជាផែនទីបង្ហាញផ្លូវសម្រាប់ពង្រឹងផលិតភាពនៃផលិតកម្មស្វាយចន្ទីកាត់បន្ថយថ្លៃដើមក្នុងផលិតកម្មមានផលិតផលមានគុណភាព សុវត្ថិភាព រស់ជាតិប្រកួតប្រជែង ទាក់ទាញការវិនិយោគ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មកែច្នៃ បង្កើនតម្លៃបន្ថែម ជំរុញការនាំចេញ ជាមួយការធ្វើពិពិធកម្មទីផ្សារ និងលើកកម្ពស់ឧត្តមភាពដណ្ដើមភាពឈ្នះ។៚

*ដោយ ផាត់ លេង (ក.ស.វ. - ក្រុម ២)*

# IV- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០២២



ការវិភាគនេះ ត្រូវបានរៀបចំឡើងក្រោយកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ) ដើម្បីពិភាក្សាលើស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃអង្គារ ២ រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ពស. ២៥៦៦ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ឆាយលី** ប្រធាន ក.ស.វ. ដែលមានសមាសភាពចូលរួម អនុប្រធានប្រចាំការ អនុប្រធាន ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារ ក.ស.វ. សមាជិក សមាជិកា ទីប្រឹក្សាបច្ចេកទេសនៃ ក.ស.វ. ព្រមទាំងអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក មន្ត្រីបច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាន នៃ ក.ស.វ និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធតាមរយៈប្រព័ន្ធហ្ស៊ូម។ ការវិភាគនេះផ្អែកលើទិន្នន័យព័ត៌មានដែលទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ពីអង្គប្រជុំទាំងមូល។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➢ អតិផរណាឆ្នាំ២០២២មានអត្រាស្មើនឹង៥,៣% ក្នុងនោះក្រុមទំនិញដែលឡើងថ្លៃលើសអត្រាអតិផរណាសរុបមាន សម្លៀកបំពាក់និងស្បែកជើង ការដឹកជញ្ជូន ការកម្សាន្តនិងវប្បធម៌ ភោជនីយដ្ឋាន និងផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត។

តារាង ១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញ

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ២០២២ | អតិផរណាឆ្នាំ២០២១ |
|---|---|---|---|
| | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ៥,៣% | ២,៩% |
| ១ | ដឹកជញ្ជូន | ៩,៤% | ៨,៨% |
| | ក្នុងនោះប្រេងសាំង | ២២,៩% | ២៦,៥% |
| ២ | សម្លៀកបំពាក់ និងស្បែកជើង | ៧,៤% | ៤,៩% |
| ៣ | ភោជនីយដ្ឋាន | ៦,៥% | ០,៨% |
| ៤ | លំនៅឋាន ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងៗ | ៥,៦% | ២,៩% |
| ៥ | ការកម្សាន្ត និងវប្បធម៌ | ៥,៦% | ០,៨% |
| ៦ | ម្ហូបអាហារ | ៥,០% | ២,៨% |
| ៧ | គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ៣,៦% | ១,០% |
| ៨ | ទំនិញនិងសេវាកម្មផ្សេងៗ | ៣,៤% | ៥,២% |
| ៩ | សុខាភិបាល | ២,៦% | ១,២% |
| ១០ | ការសិក្សា | ២,១% | ០,៣% |
| ១១ | ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ១,១% | ១,០% |
| ១២ | ទូរគមនាគមន៍ | ០,០០២% | -០,៣% |

⇨ មុខទំនិញដែលឡើងថ្លៃគួរឲ្យកត់សម្គាល់មាន ប្រេងសាំង ២២,៩% ប្រេងម៉ាស៊ូត ៤២,១% និងឧស្ម័ន ១៧,៦% ។

តារាង១.២. អតិផរណាប្រចាំខែ ឆ្នាំ២០២០-២០២២ (កំណើនថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២២ | ខែដូចគ្នាឆ្នាំមុន | ៤,១% | ៦,៣% | ៧,២% | ៧,៣% | ៧,២% | ៧,៨% | ៥,៤% | ៤,៩% | ៤,៤% | ៣,៦% | ៣,២% | ២,៩% | ៥,៣% |
| ២០២១ | ខែដូចគ្នាឆ្នាំមុន | ២,៦% | ១,៧% | ២,១% | ២,៧% | ៣,០% | ២,៧% | ៣,៣% | ៣,៤% | ៣,០% | ២,៩% | ៣,៨% | ៣,៧% | ២,៩% |
| ២០២០ | ខែដូចគ្នាឆ្នាំមុន | ៣,៦% | ២,៧% | ២,៨% | ១,៩% | ២,៤% | ៣,២% | ៣,១% | ២,៤% | ២,៩% | ៣,៧% | ៣,៧% | ២,៩% | ៣,០% |

➢**អត្រាប្តូរប្រាក់:**

⇨ប្រាក់រៀលមានការធ្លាក់ថ្លៃ១,១%ធៀបនឹងប្រាក់ដុល្លារអាមេរិក ប៉ុន្តែមានការឡើងថ្លៃ២,៥%ធៀបនឹងប្រាក់បាត ឡើងថ្លៃ២,៨%ធៀបនឹងប្រាក់ដុង និងឡើងថ្លៃ៧,៥%ធៀបនឹងប្រាក់យ៉ន់។ នាចុងឆ្នាំ២០២២ អត្រាប្តូរប្រាក់រៀល មានស្ថានភាពដូចខាងក្រោម:

- ▪ប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានអត្រា៤ ១១៧៛/ដុល្លារ
- ▪ ប្រាក់រៀលធៀបនឹងដុងវៀតណាមមានអត្រា០,១៧៤៛/ដុង
- ▪ប្រាក់រៀលធៀបនឹងបាតថៃមានអត្រា១១៩៛/បាត
- ▪ប្រាក់រៀលធៀបនឹងយ៉ន់ចិនមានអត្រា៥៩១៛/យ៉ន់។

## ២. ស្ថានភាពថវិកាជាតិ

➢យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិ ក្នុងឆ្នាំ២០២២នេះ អនុវត្តបាន ចំនួន ២៦ ១៩២,៣ ប៊ីលានរៀល (គិតជាដុល្លារអាមេរិក ៦ ៥៤៨,១ លានដុល្លារ) ស្មើនឹង ១០៥,៩% នៃផែនការ ក្នុងនោះចំណូលចរន្ត ២៤ ៤៩៦,៥ ប៊ីលានរៀល (គិតជាដុល្លារអាមេរិក ៦ ១២៤,១ លានដុល្លារ) ស្មើនឹង ១១០,៦% នៃផែនការ និងចំណូលមូលធន១ ៦៩៥,៨ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៤២៣,៩លានដុល្លារ) ស្មើនឹង ៦៥,៩% នៃផែនការ ។

➢ បើធៀបនឹងឆ្នាំ២០២១ ចំណូលថវិកាជាតិកើនឡើង២៣,៥%ក្នុងនេះ ចំណូលចរន្តកើនឡើង២២,៤% និងចំណូលមូលធន កើនឡើង៥៤,៨%។

⇨ការកើនឡើងនៃចំណូលចរន្តជាចម្បងបណ្តាលមកពីចំណូលសារពើពន្ធកើនឡើង២២,៨% និងចំណូលមិនមែនសារពើពន្ធ កើនឡើង១៨,៥%។

តារាង២.១. ចំណូលសារពើពន្ធ ឆ្នាំ២០២២

| មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២១ | មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២១ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** * | ១១១,២% | +២២,៨% | **ចំណូលមិនមែនសារពើពន្ធ*** | ១០៤,១% | +១៨,៥% |
| ✓**ពន្ធ និងអាករគយ** ** | — | +១៩,២% | ✓កាស៊ីណូ | ៥០,០% | +៨៤២,៧% |
| –ពន្ធគយ (របបនាំចូល) | — | +២៥,៨% | ✓ចំណូលពីអជ្ញាបណ្ណក្នុងស្រុក | ៣០៩,២% | -២៩,៥% |
| –អាករពិសេសលើរបបនាំចូល | — | +១៩,២% | ✓កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ៥៧,៥% | -១០,៧% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | — | +១៨,៩% | ✓ វគ្គាប្រមាញ់ | ៧១,២% | -៥៨,២% |
| –អាករនាំចេញ | | +២៩,៤% | ✓សម្បទានរ៉ែ | ៧១,១% | +៤១,២% |
| –អាករបន្ថែមលើគេលសិលា | | -៩,០% | ✓អាកាសចរណ៍ស៊ីវិល | ៨៩,៥% | +១៣៤,៩% |
| ✓**ចំណូលពន្ធដារ** *** | ១១៨,៨% | +២៤,១% | ✓ផលទុនទេសចរណ៍ | ៤០,៧% | កើនគំហុក |
| –ពន្ធលើប្រាក់បៀវត្ស | ១២២,៧% | +២៣,២% | ✓ ត្រួតពិនិត្យគុណភាពផលិតផល | ៩៥,៩% | +១០,៥% |
| – ពន្ធលើប្រាក់ចំណូល | ១៣៨,២% | +២៦,៧% | ✓ ជួលរោងចក្រ សហគ្រាសសម្ភារៈ | ១០០,៩% | +២៧,២% |
| – អាករលើតម្លៃបន្ថែម | ៩៩,៥% | +៣២,៤% | ✓ ប្រៃសណីយ៍ និងទូរគមនាគមន៍ | ១១២,០% | +៤,៤% |
| –អាករពិសេស | ៩២,៤% | +២៦,៣% | | | |
| –ពន្ធថវិកាខេត្ត-រាជធានី | ១២៤,១% | +២០,៦% | | | |

* តួលេខរតនាគាជាតិ **តួលេខអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ***តួលេខអគ្គនាយកដ្ឋានពន្ធដារ

➢ចំណាយថវិកាជាតិក្នុងឆ្នាំ២០២២នេះ អនុវត្តបាន ២២ ១០៥,៣ ប៊ីលានរៀល (គិតជាដុល្លារអាមេរិក ៥ ៤២៦,៣ លានដុល្លារ) ស្មើនឹង ៨២,៦% នៃផែនការ ក្នុងនោះ ចំណាយចរន្ត ១៦ ៦៩៣,៥ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៤ ១៧៣,៤ លានដុល្លារ) ស្មើនឹង ៨៧,៣% នៃផែនការ និងចំណាយមូលធន ៥ ៤១១,៨ ប៊ីលានរៀល ស្មើនឹង ៧០,៧% នៃផែនការ។

➢បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិថយចុះ៣,៦% ក្នុងនោះចំណាយចរន្តថយចុះ១,៧% និងចំណាយមូលធនថយចុះ៨,៩%។

➢ជាលទ្ធផល ថវិកាជាតិនាឆ្នាំ២០២២ មានអតិរេកចំនួន ៤ ០៨៦,៩ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១ ០២១,៧ លានដុល្លារ អាមេរិក)។ ប៉ុន្តែគួរកត់សម្គាល់ថាតួលេខចំណាយមូលធនក្នុងតារាងទិន្នន័យឆ្លុះបញ្ចាំងតែចំណាយដែលបានឆ្លងកាត់ រតនាគារជាតិតែប៉ុណ្ណោះ។

## ៣. ស្ថានភាពរូបិយវត្ថុ

➢សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២២ មានសូចនាកររូបិយវត្ថុដូចខាងក្រោម :

⇨រូបិយវត្ថុ □2មានចំនួន ១៧១ ៩៦២,១ ប៊ីលានរៀល កើនឡើង ៨,៣% ធៀបនឹងឆ្នាំ២០២១។




តារាង៣.១. កំណើនសូចនាកររូបិយវត្ថុ ២០១៨-២០២២ ធៀបនឹងឆ្នាំមុន

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| □2 | +២៦,៦% | +១៨,២% | +១៥,៣% | +១៦,៣% | +៨,៣% |
| *សមាមាត្រ □2 ក្នុងផសស* | ១០០,៧% | ១០៧,៧% | +១២៥,២% | +១៣៦% | +១៤២,១% |
| □1 | +២២,៤% | +២៥,០% | +៩,១% | +១៥,៣% | -៧,៧% |
| *សមាមាត្រ □1 ក្នុងផសស* | ២៨,៦% | ៣២,៤% | ៣៥,៦% | ៣៨,៣% | ៣៤,២% |
| រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ | +១០,៨% | +៣២,១% | +១៣,២% | +៨,៣% | -៣,១% |
| ប្រាក់បញ្ញើចរន្ត | +២៨,៦% | +២១,៨% | +៧,០% | +១៨,៩% | -៩,៩% |
| ប្រាក់បញ្ញើផ្សេងទៀត | +២៨,៣% | +១៥,៤% | +១៧,៩% | +១៦,៧% | +១៤,៦% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +៣០,២% | +១៥,៤% | +១៣,៩% | +១៥,០% | +៨,៤% |

⇨ក្នុងឆ្នាំ២០២២ រូបិយវត្ថុទូទៅ□2 មានចំនួនប្រហែល ១៤២,១%នៃផសស ប៉ុន្តែ**សមមាត្រ**□1ក្នុងផសស មានត្រឹមតែ ៣៤,២% ប៉ុណ្ណោះ។

➢ទុនបំរុងជារូបិយបណ្ណបរទេសដុល មានចំនួន ១៧ ៨០៥,២ លានដុល្លារថយចុះ១២,១% ធៀបនឹងឆ្នាំ ២០២១។

➢ទុនបំរុងជារូបិយបណ្ណបរទេសសុទ្ធខាងលើ អាចធានាការនាំចូលបានចំនួន ៧,៥ ខែ។

➢ការផ្តល់ឥណទានដោយធនាគារពាណិជ្ជមានចំនួន ១៩៤ ២៤២,៦ ប៊ីលានរៀលកើនឡើង ១៨,១% ធៀបនឹងឆ្នាំមុន។

តារាង៣.២. អត្រាការប្រាក់ប្រចាំឆ្នាំ:

| ប្រភេទអត្រាការប្រាក់ | អត្រាឆ្នាំ ២០២២ | អត្រាឆ្នាំ ២០២១ | %Δ(២០២២/២០២១) |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,១% | ៤,៨% | ២៧,៦% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១០,៣% | ៩,៩% | ៣,៩% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៥,៦% | ៤,០% | ៤០,៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,៧% | ៨,៤% | ៣,៦% |
| កម្ចីជារៀលនៅអិល អូ អិល ស៊ី | ១៨,០% | ១៧,៧% | ១,៩% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៦% | ១៨,០% | -២,៣% |
| កម្ចីជារៀលនៅប្រាសាក់ | ១២,៥% | ១៦,៦% | -២៤,៧% |

## ៤. ស្ថានភាព កសិកម្ម ឧស្សាហកម្ម រ៉ែ និងថាមពល សេវាកម្ម និងវប្បធម៌

➢***កសិកម្ម***

⇨ផលិតផលស្រូវប្រចាំឆ្នាំ២០២២ មានចំនួន១១ ៦២៤ ពាន់តោន ថយចុះ៤,៨% ធៀបនឹងឆ្នាំ២០២១

⇨ក្នុងឆ្នាំ២០២២ ផលិតផលកៅស៊ូមានចំនួន៣៨២,០ពាន់តោន កើនឡើង ៣,៨% ធៀបនឹងឆ្នាំ២០២១។ ផ្ទៃដីចៀរជ័រមានចំនួន៣១៥,៣ ពាន់ហិកតាកើនឡើង១,៦%ធៀបនឹងឆ្នាំ២០២១ និងផ្ទៃដីដាំដុះសរុបមាន ៤០៤,៦ ពាន់ហិចតាកើនឡើង០,១%ធៀបនឹងឆ្នាំ២០២១។

⇨ ផលិតកម្មនេសាទឆ្នាំ២០២២ មានចំនួន ៨៦២,២ ពាន់តោនមានការកើនឡើង០,៧% ធៀបនឹងឆ្នាំ ២០២១។

➢***ឧស្សាហកម្ម***

⇨ចំនួនរោងចក្រសរុបដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្មមានចំនួន ១ ៩៨២ រោងចក្រ កើនឡើង ៥,៥%ធៀបនឹងឆ្នាំ២០២១។

⇨ផលិតកម្មវាយនភណ្ឌនិងស្បែកជើងសម្រេចបាន៩ ៩០២,៨ លានដុល្លារ កើនឡើង ៤,២% ធៀបនឹងឆ្នាំ២០២១។

⇨ ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន :២០២២* | *ចំនួន:២០២១* | %Δ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ១ ៩៨២ | ១ ៨៧៩ | +៥,៥% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ១៨៦ | ១៦៣ | +១៤,១% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១ ២២៩ | ១ ២៣០ | -០,១% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១ ៤២៣ | ១ ៣០១ | +៩,៤% |

➢ ***រ៉ែនិងថាមពល***

⇨ ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១៤ ៧១៤,0 GWh កើនឡើង ១៤,១% ធៀបនឹងឆ្នាំ២០២១។ ក្នុងនោះ៖

- វារីអគ្គិសនីមានចំនួន ៨ ៤៣៥,៤ GWh កើនឡើង ១៧,៣% ធៀបនឹងឆ្នាំ២០២១ (ស្មើ៥៧,៣% នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- ធ្យូងថ្មមានចំនួន ៣ ១៣៣,៥ GWh ថយចុះ៩,៣% ធៀបនឹងឆ្នាំ២០២១ (ស្មើ២១,៣%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- ថាមពលពន្លឺព្រះអាទិត្យ (Solar) មានចំនួន ៦៨២,0 GWh កើនឡើង ១២,៨% ធៀបនឹងឆ្នាំ២០២១ (ស្មើ៤,៦%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- នាំចូលពីប្រទេសជិតខាងមានចំនួន ២ ០៦៧,២ GWh កើនឡើង ៩៩,៥% ធៀបនឹងឆ្នាំ២០២១ (ស្មើ១៤,0%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ៣៩៥,៩ GWh ថយចុះ៣៤,២% ធៀបនឹងឆ្នាំ២០២១ (ស្មើ២,៧%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)។

⇨ ផលិតកម្មស៊ីម៉ង់ត៍ ក្នុងឆ្នាំ២០២២ មានចំនួន ៨ ៥២៦,៥ ពាន់តោនមានការថយចុះ៤,៧% ធៀបនឹងឆ្នាំ២០២១។

➢**សំណង់ (ការអនុញ្ញាត)**:

សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន៧ ២៣៣,៩ ពាន់ម២ មានការថយចុះ៤៤,៣% ធៀបនឹងឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ២ ៩៥២,0 លានដុល្លារមានការថយចុះ៤៤,៧% បើធៀបនឹងឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

| *ប្រភេទសំណង់* | ពាន់ម២ :២០២២ | ពាន់ម២ :២០២១ | % ∆ |
|---|---|---|---|
| លំនៅឋាន | ៣ ៩៥៤,៩ | ៧ ៣៩៣,0 | -៤៦,៥% |
| ឧស្សាហកម្ម | ១ ៥៨០,៩ | ២ ៥៤៤,៥ | -៣៧,៩% |
| ពាណិជ្ជកម្ម | ១ ១២៦,៥ | ២ ០៤២,២ | -៤៤,៨% |
| ទេសចរណ៍ | ១៤៨,៤ | ៤១៧,៥ | -៦៤,៥% |
| ... | ... | ... | ... |
| អនុញ្ញាតសរុប | ៧ ២៣៣,៩ | ១២ ៩៩៨,១ | -៤៤,៣% |

ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមឆ្នាំ២០២២ នេះគឺសំណង់លំនៅឋាន ៥៤,៧% និងសំណង់ឧស្សាហកម្ម២១,៩% នៃផ្ទៃក្រឡាសរុប។

➢**ការចុះបញ្ជីនិងលុបចេញពីបញ្ជី**

| *ប្រភេទ* | ២០២២ (*ចំនួន*) | ២០២១ (ចំនួន) | *%∆* |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៤ ៨៩១ | ៤ ៧៤៧ | +៣,0% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៨១៤ | ៦១៧ | +៣១,៩% |
| ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | ៦ ២៧៥ | — | — |
| ក្នុងនោះ លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ៥ ៦០៧ | ៦ ៨១៤ | -១៨,0% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៥ ៨៥៧ | | |

## ➢ ការងារ

| ប្រភេទ | ២០២២ (នាក់) | ២០២១ (នាក់) | %∆ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ(ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១៨ ២៧៨ | ៤ ៨២៣ | +២៧៩,០% |
| អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ៤៤៧ ២៩៨ | ១៤៣ ៣៧១ | +២១២,០% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៤១៣ ៥៥៦ | ១៤០ ០៩០ | +១៩៥,២% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៣៣ ៧៤២ | ៣ ២៨១ | +៩២៨,៤% |

## ➢ វិនិយោគ:គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក.

| ប្រភេទ | ២០២២ | ២០២១ | %∆ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៤ ០៣២,៩ | ៤ ៣៥៥,៤ | -៧,៤% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៥២,៣ | ១៣៤,៦ | +១៣,២% |
| វិស័យឧស្សាហកម្ម | ១ ៥៦៥,៣ | ២ ១៧១,៥ | -២៧,៩% |
| (ក្នុងនោះក្នុងតំបន់សេដ្ឋកិច្ចពិសេស) | ៥៨៨,០ | ៧៥៥,៦ | +៣៩,៨% |
| វិស័យទេសចរណ៍ | ៤៩៦,៦ | ១២៧,៨ | +២៨៨,៥% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១ ៨១៨,៦ | ១ ៩២១,៤ | -៥,៤% |
| ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន) | ១៨៦ | ១៦៩ | +១០,១% |
| ចំនួនពលករ (ពាន់នាក់) | ១៤៤,០ | ១១៣,០ | +២៧,៤% |

## ➢ សេវាកម្មនិងទេសចរណ៍

➢ **ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ)មានចំនួន១២ ៣៧៤,៥ពាន់តោនកើនឡើង១៤,២%ធៀបនឹងឆ្នាំ២០២១។ ក្នុងនោះ:

| ប្រភេទ | ២០២២ (ពាន់តោន) | ២០២១ (ពាន់តោន) | %∆ |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ៤ ០៤៤,៦ | ៣ ៨៤៥,៨ | +៥,២% |
| កំពង់ផែកំពង់សោម | ៨ ៣២៩,៩ | ៦ ៩៩០,៣ | +១៩,២% |

## ➢ ការចុះបញ្ជី និងចរាចរណ៍

### ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ២០២២ (ចំនួន) | ២០២១ (ចំនួន) | %∆ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៤៦៧,១ | ៤៣២,៣ | +៨,១% |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ៨៧,៥ | ៧៤,០ | +១៨,៣% |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ២ ៩៥០ | ២ ៦៧០ | +១០,៥% |

## ➢ ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ២០២២ | ២០២១ | %∆ |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ២១៩,០ | ១៤១,៩ | +៥៤,៣% |
| ក្នុងនោះទទួល | ៤៤,២ | ៣៣,៦ | +៣១,៣% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៤១៨,៨ | ៣៣០,៦ | +២៦,៧% |
| ក្នុងនោះទទួល | ២២៧,៤ | ២៧៩,៩ | -១៨,៨% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ៧ ៤៧២,៦ | ១១ ៨៦៨,៣ | -៣៧,០% |
| ក្នុងនោះហៅចូល | ៣ ១៦៤,៤ | ៥ ២៩២,៦ | -៤០,២% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១២ ៩៩១,៣ | ២៦ ៧៦១,៩ | -៥១,៥% |
| ក្នុងនោះហៅចូល | ១២ ៧៧០,៣ | ២៦ ៤៤៧,៧ | -៥១,៧% |

## ➢អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ២០២២ (ពាន់នាក់) | ២០២១ (ពាន់នាក់) | %Δ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៤៦,៧ | ១,៣ | កើនគំហុក |
| ភ្ញៀវទេសចរបរទេសទិញបណ្ណទស្សនាអង្គរ | ២៨៧,៥ | ១២,៩ | កើនគំហុក |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ៩៧,៥ | ៤៨,៤ | +១០១,៥% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១០៣,២ | ៨,០ | កើនគំហុក |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២ ២៦៣,៥ | ២៥៥,០ | +៧៨៧,៥% |
| ទំនិញដឹកជញ្ជូនតាមផ្លូវអាកាស | ៥៥,០ | ៧០,៨ | -២២,៣% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៩៧០,៣ | ៣០,៥ | កើនគំហុក |
| ចំនួនទេសចរផ្ទៃក្នុង | ១៥ ៨១១,៣ | ៤ ៩៤២,៤ | +២១៩,៩% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ២ ២៧៦,៥ | ១៩៦,៥ | កើនគំហុក |
| ✓តាមផ្លូវអាកាស | ៧៩១,៦ | ៩៩,៨ | +៦៩៣,០% |
| ✓ តាមផ្លូវគោក និងទឹក | ១ ៤៨៥,០ | ៩៦,៧ | កើនគំហុក |

## ៥. ស្ថានភាពពាណិជ្ជកម្ម

▪យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០២២ មានចំនួន ១១៤ ០០៥,០ប៊ីលានរៀល (គិតជាដុល្លារអាមេរិក ២៨ ៥០១,៣ លានដុល្លារ) កើនឡើង ០,៣% បើធៀបនឹងឆ្នាំ២០២១ក្នុងនោះ ៖

| មានការកើនឡើង | មានការថយចុះ |
|---|---|
| ប្រេងឥន្ធនៈ +២,២% | ប្រេងម៉ាស៊ូត -៨,៩% |
| ប្រេងសាំង +២០,៤% | ប្រេងខ្មៅ-១៧,៩% |
| ប្រេងសាំងយន្តហោះ +១១៣,២% | ស៊ីម៉ងត៍ -៥៥,០% |
| ឧស្ម័ន+១២,០% | គ្រាក់ទ័រ និងគោយន្ត -១២,០% |
| ដែកសំណង់ +១១,៦% | អង្ករ -៣៣,២% |
| រថយន្តសរុប +៤០,៥% | ផ្លែឈើ និងបន្លែ -៧២,៧% |
| រថយន្តទេសចរណ៍ +៤៧,៥% | ជីកសិកម្ម -២៦,០% |
| រថយន្តដឹកជញ្ជូន +៣២,៣% | នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម -១៩,៩% |
| ស្រូវសាឡី +៩,១% | |
| ថ្នាំកសិកម្ម +២,៨% | |
| នាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +០,៧% | |

▪**ការនាំចេញ**ឆ្នាំ២០២២មានចំនួន ៨៤ ២៣៤,៦ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ២១ ០៥៨,៧ លានដុល្លារ) ស្មើនឹង ៧៣,៩% នៃការនាំចូល មានការកើនឡើង ១៦,៩% ធៀបនឹងឆ្នាំ២០២១ក្នុងនោះ ៖

| ទំនិញ | %Δ ធៀបនឹង-២០២១ | ទំនិញ | %Δ ធៀបនឹង-២០២១ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៤៣,៥% | ផលិតផលនេសាទ | -១៨,២% |
| វាយនភណ្ឌនិងស្បែកជើង | +១៤,៦% | កៅស៊ូ | +៧,៧% |
| អង្ករ | +០,៩% | | |

# ១- សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ផ្លាស់ប្តូរពិភពលោកដូចខាងក្រោម៖

## ១-ម្ហូបអាហារ

សង្គ្រាមបានជួយជំរុញឱ្យតម្លៃគ្រាប់ធញ្ញជាតិពិភពលោកកើនឡើងខ្ពស់ ដោយផ្តល់សារៈសំខាន់នៃប្រទេសរុស្ស៊ី និងអ៊ុយក្រែនជាអ្នកនាំចេញដំណាំអាហាររួមទាំងស្រូវសាលីផងដែរ។អង្គការសហប្រជាជាតិបានព្រមានថា មនុស្សរាប់លាននាក់ ជាពិសេសនៅផ្នែកខ្លះនៃទ្វីបអាហ្វ្រិក និងមជ្ឈិមបូព៌ា ត្រូវបានគំរាមកំហែងដោយទុរ្ភិក្ស។ កាលពីខែកក្កដា ទីក្រុងមូស្គូ និងទីក្រុង Kyiv បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដើម្បីបញ្ចេញគ្រាប់ធញ្ញជាតិរាប់លានតោនដែលជាប់គាំងនៅក្នុងកំពង់ផែសមុទ្រខ្មៅរបស់អ៊ុយក្រែនដោយសារតែការបិទផ្លូវរបស់កងទ័ពជើងទឹករុស្ស៊ី។ទោះបីជារុស្ស៊ីបានផ្អាកការចូលរួមរបស់ខ្លួនក្នុងកិច្ចព្រមព្រៀងមួយរយៈពេលខ្លីក្នុងខែតុលាក៏ដោយ ប៉ុន្តែកិច្ចព្រមព្រៀងនេះ បានធ្វើឡើងយ៉ាងទូលំទូលាយ ហើយតម្លៃគ្រាប់ធញ្ញជាតិពិភពលោកបានត្រលប់ទៅកម្រិតមុនសង្គ្រាមវិញ។

## ២-ថាមពល

សង្គ្រាមបានបញ្ចេញវិបត្តិថាមពលពិភពលោកដ៏អាក្រក់បំផុតចាប់តាំងពីទសវត្សរ៍ឆ្នាំ 1970។តម្លៃថាមពលបានកើនឡើងក្នុងផ្នែកជាច្រើននៃពិភព លោក ដោយសារប្រទេសនានាកាត់បន្ថយឬកាត់បន្ថយការទិញឥន្ធនៈហ្វូស៊ីលរបស់រុស្ស៊ី។ នៅអឺរ៉ុប វិក្កយបត្រឧស្ម័នកើនឡើងជិតទ្វេដង ហើយថ្លៃអគ្គិ- សនីបានកើនឡើងប្រហែល 70ភាគរយក្នុងរយៈពេលប្រាំមួយខែដំបូងនៃសង្គ្រាម។អ្នកការទូតសហភាពអឺរ៉ុបកាលពីខែធ្នូបានព្រមព្រៀងគ្នាលើការកំណត់តម្លៃ 60 ដុល្លារក្នុងមួយបារ៉ែលលើតម្លៃដែលប្រេងរុស្ស៊ីអាចត្រូវបានគេជួញដូរនៅខាងក្រៅប្លុកក្នុងការដេញថ្លៃមួយផ្សេងទៀតដើម្បីដកហូតប្រាក់ចំណូលពីទីក្រុងម៉ូស្គូសម្រាប់សង្គ្រាម។ ប៉ុន្តែដោយមានការផ្គត់ផ្គង់សកលកាន់តែតឹងរ៉ឹង រុស្ស៊ីនៅតែជាប្រទេសនាំចេញដ៏លេចធ្លោដោយលក់ប្រេងនិងឧស្ម័នកាន់តែច្រើនទៅកាន់ប្រទេសចិន និងឥណ្ឌាក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ។

## ៣-អតិផរណា

សេដ្ឋកិច្ចពិភពលោកទើបតែងើបចេញពីជំងឺរាតត្បាត ហើយវិបត្តិថាមពល និងកំណើនយឺតបានរួមចំណែកដល់អតិផរណាខ្ពស់។ ការឡើងថ្លៃបានស៊ីដាច់ការសន្សំនិងប្រាក់បៀវត្សរ៍របស់ប្រជាជនដែលបណ្តាលឱ្យប្រាក់ឈ្នួលពិតប្រាកដធ្លាក់ចុះនៅក្នុងប្រទេសជាច្រើន និងកាត់បន្ថយអំណាចទិញ។ អតិ- ផរណាខ្ពស់បានក្លាយជាការឈឺក្បាលផ្នែកនយោបាយសម្រាប់មេដឹកនាំក្នុងប្រទេសនានា រួមទាំងសហរដ្ឋអាមេរិក បារាំង និងអង់គ្លេស ដោយរដ្ឋាភិបាលបង្កើនការចំណាយដើម្បីបន្ធូរបន្ថយការឈឺចាប់ សម្រាប់គ្រួសារ និងអាជីវកម្មដោយប្រើកំណត់តម្លៃប្រាក់ឧបត្ថម្ភ និងការកាត់បន្ថយពន្ធ។

## ៤-NATO

ប្រធានាធិបតី Joe Biden បាននិយាយនៅនៅទីក្រុងWarsawប្រទេសប៉ូឡូញថា“NATOគឺខ្លាំងជាងអ្វីដែលធ្លាប់មាន”។ ប្រធានាធិបតីរុស្ស៊ី លោក VladimirPutinប្រហែលជាសង្ឃឹមថាការឈ្លានពានរបស់លោកនឹងធ្វើឱ្យមានការបែកបាក់កាន់តែខ្លាំងនៅក្នុងអង្គការNATOប៉ុន្តែសម្ព័ន្ធភាពនេះត្រូវបានរួប

រួម។ ប្រទេសហ្វាំងឡង់ដែលមានព្រំប្រទល់ជាប់នឹងរុស្ស៊ីបានបោះបង់ចោលគោលនយោបាយអព្យាក្រឹតភាពរបស់ខ្លួន ហើយបានអនុវត្តដើម្បីចូលរួមសម្ព័ន្ធភាព ដូចប្រទេសស៊ុយអែតដែរ។ មេដឹកនាំអង្គការ NATOបាននិយាយថាពួកគេរំពឹងថាប្រទេសទាំងពីរនឹងឈ្នះការយល់ព្រម បើទោះបីជាតួកគីបានលើកឡើងពីការជំទាស់លើការប្រព្រឹត្តរបស់ស៊ុយអែតលើក្រុមឃឺដ ដែលទីក្រុងអង់ការ៉ាចាត់ទុកថាជាភេរវករក៏ដោយ។ កាលពីខែកញ្ញា អ៊ុយក្រែនបានដាក់ពាក្យចូលរួម បើទោះបីជាការដេញថ្លៃរបស់ខ្លួនត្រូវបានចាត់ទុកថាជាការប្រើពេលដ៏វែងក៏ដោយ។

## ៥-អឺរ៉ុប

ប្រជាជនអ៊ុយក្រែនជាង ៨ លាននាក់បានភៀសខ្លួនជាជនភៀសខ្លួនទៅកាន់តំបន់ផ្សេងទៀតនៃទ្វីបអឺរ៉ុប ជាពិសេសក្នុងដំណាក់កាលដំបូងនៃសង្គ្រាម នេះបើយោងតាមទីភ្នាក់ងារជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ។៥លាននាក់ផ្សេងទៀតត្រូវបានគេប៉ាន់ស្មានថាត្រូវផ្លាស់ទីលំនៅក្នុងប្រទេសអ៊ុយក្រែន។ ចំនួនជនភៀសខ្លួនខ្ពស់បំផុតគឺច្រើនជាង 1.5 លាននាក់ត្រូវបានចុះឈ្មោះនៅក្នុងប្រទេសប៉ូឡូញ។ក្នុងពេលជាមួយគ្នានោះសង្គ្រាមបានបង្កើនឥទ្ធិពលលើទ្វីបប៉ូឡូញ និងរដ្ឋបាល់ទិក ដែលបានឱបក្រសោបការការពារដ៏រឹងមាំរបស់អ៊ុយក្រែន និងបានជំរុញឱ្យមានការផ្គត់ផ្គង់ជំនួយយោធាកាន់តែច្រើន និងលឿនជាងមុន។ មេដឹកនាំបែបប្រពៃណីរបស់អឺរ៉ុប បារាំង និងអាឡឺម៉ង់ បានតស៊ូដំបូងជាមួយនឹងភារកិច្ចដ៏លំបាកក្នុងការតម្រង់ទិសគោលនយោបាយយូរអង្វែងរបស់ពួកគេនៃរចនាសម្ព័ន្ធសន្តិសុខអឺរ៉ុប ដែលរួមបញ្ចូលកិច្ចសហប្រតិបត្តិការជាមួយរុស្ស៊ី។

## ៦-ចិន

ប្រទេសចិនបានដើរលើផ្លូវដ៏ល្អមួយក្នុងអំឡុងពេលសង្គ្រាមដោយអំពាវនាវឱ្យមានសន្តិភាពខណៈពេលដែលបដិសេធមិនរិះគន់រុស្ស៊ីដែលជាដៃគូដ៏សំខាន់កាន់តែខ្លាំងឡើង។ មន្ត្រីការទូតកំពូលរបស់ចិន លោក Wang Yi ក្នុងដំណើរទេសចរណ៍នៅអឺរ៉ុប បានប្រាប់សមភាគីអ៊ុយក្រែនថា លោកមិនចង់ឃើញសង្គ្រាម «អូសបន្លាយ និងកើនឡើង»។ ក្នុងពេលជាមួយគ្នានេះ ប្រទេសចិនកំពុងធ្វើសមយុទ្ធយោធារួមគ្នាជាមួយរុស្ស៊ី និងអាហ្វ្រិកខាងត្បូង ហើយមេដឹកនាំចិន Xi Jinping ត្រូវបានគេរំពឹងថានឹងធ្វើទស្សនកិច្ចផ្លូវរដ្ឋទៅកាន់ទីក្រុងម៉ូស្គូនៅនិទាឃរដូវ។ រដ្ឋបាលលោក Biden កំពុងឃ្លាំមើលយ៉ាងដិតដល់ចំពោះសញ្ញាដែលបង្ហាញថាប្រទេសចិនអាចឆ្លងកាត់ខ្សែបន្ទាត់ក្នុងការផ្តល់ការគាំទ្រផ្នែកយោធាដោយផ្ទាល់ដល់ប្រទេសរុស្ស៊ីហើយបានព្រមានខ្លួនប្រឆាំងនឹងការធ្វើដូច្នេះប៉ុន្តែទីក្រុងប៉េកាំងបានរុញច្រានយ៉ាងខ្លាំងក្លា ប្រឆាំងនឹងការចោទប្រកាន់របស់សហរដ្ឋអាមេរិក។

ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

ប្រភព៖ The New York Times, 25 Feb 2023

## ២- ប្រទេសរុស្ស៊ីឆ្លើយតបនឹងកញ្ចប់ទណ្ឌកម្មសេដ្ឋកិច្ច ខណៈដែលប្រទេសចិនច្រានចោលការសន្ទនាយោធាអាមេរិក-ចិន

១-ក្រសួងការបរទេសរុស្ស៊ី បាននិយាយថា ដើម្បីឆ្លើយតបទៅនឹងសកម្មភាពមិនរាក់ទាក់របស់សហភាពអឺរ៉ុប ទីក្រុងមូស្គូបានពង្រីកបញ្ជីបញ្ឈប់តំណាងស្ថាប័នអឺរ៉ុបនិងរដ្ឋជាសមាជិកសហភាពអឺរ៉ុបនោះត្រូវបានហាមឃាត់មិនឱ្យចូលប្រទេសរុស្ស៊ី។ "សហភាពអឺរ៉ុបបន្តការប៉ុនប៉ងរបស់ខ្លួន ដើម្បីដាក់សម្ពាធលើប្រទេសរុស្ស៊ីតាមរយៈវិធានការរឹតត្បិតជាឯកតោភាគី។ នៅថ្ងៃទី16 ខែធ្នូ ឆ្នាំ2022 បណ្តាប្រទេសសហភាពអឺរ៉ុប បានអនុម័តកញ្ចប់ទណ្ឌកម្មទី៩។រុស្ស៊ីចាត់ទុកថាសកម្មភាពរបស់សហភាពអឺរ៉ុបបែបនេះមិនស្របច្បាប់ប៉ះពាល់ដល់សិទ្ធិស្របច្បាប់អន្តរជាតិនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ"។

យោងតាមបេសកកម្មការទូត "សភាអឺរ៉ុប ក៏កំពុងបន្តប្រឆាំងទង្វើឈ្លានពានរុស្ស៊ីផងដែរ ដោយបានអនុម័តនៅក្នុងកិច្ចប្រជុំរបស់ខ្លួន នៅថ្ងៃទី23 ខែវិច្ឆិកា ឆ្នាំ2022 នូវដំណោះស្រាយ "ស្តីពីការទទួលស្គាល់សហព័ន្ធរុស្ស៊ីថា ជារដ្ឋឧបត្ថម្ភអំពើភេរវកម្ម (state sponsor of terrorism)"។

ក្រសួងការបរទេសរុស្ស៊ីនិយាយថាជាស្តង់ដារទ្វេរដងនៃសហគមន៍នយោបាយលោកខាងលិច ដែលចាប់តាំងពីឆ្នាំ2014 បានបង្វែរភ្នែកទៅការសម្លាប់អ្នកស្រុក Donbas ដោយកងកម្លាំងសន្តិសុខ Kiev ។

សេចក្តីថ្លែងការណ៍បានបន្តនិយាយថា ដើម្បីឆ្លើយតបទៅនឹងសកម្មភាពមិនរាក់ទាក់ ភាគីរុស្ស៊ីបានពង្រីកបញ្ជីឈ្មោះតំណាងស្ថាប័នអឺរ៉ុប និងរដ្ឋជាសមាជិកសហភាពអឺរ៉ុប ដែលបានបំបែកខ្លួនចេញពីសហព័ន្ធរុស្ស៊ីនឹងត្រូវបានហាមឃាត់មិនឱ្យចូលប្រទេសរុស្ស៊ី។

ទីភ្នាក់ងារអនុវត្តច្បាប់នៃបណ្តាប្រទេស EU ពាក់ព័ន្ធនឹងការរៀបចំកងកម្លាំងប្រដាប់អាវុធអ៊ុយក្រែន ដែលជាផ្នែកមួយនៃបេសកកម្មរបស់ EU ដើម្បីផ្តល់ជំនួយយោធាដល់អ៊ុយក្រែនរដ្ឋាភិបាលអឺរ៉ុបនិងរចនាសម្ព័ន្ធពាណិជ្ជកម្មដែលផលិតនិងផ្គត់ផ្គង់អាវុធនិងឧបករណ៍យោធាដល់របប Kiev ក៏ដូចជាពលរដ្ឋនៃរដ្ឋសហភាពអឺរ៉ុប ត្រូវបានគេមើលឃើញនៅក្នុងវោហាសាស្ត្រប្រឆាំងរុស្ស៊ីជាលក្ខណប្រព័ន្ធ។

ក្រសួងការបរទេសរុស្ស៊ីបាននិយាយបញ្ជាក់ថា "យើងបញ្ជាក់ថារាល់សកម្មភាពដែលមិនរាក់ទាក់ពីសំណាក់ប្រទេសលោកខាងលិចនឹងបន្តទទួលបានការឆ្លើយតបទាន់ពេលវេលា និងគ្រប់គ្រាន់"។

២-ប្រព័ន្ធផ្សព្វផ្សាយអាមេរិកបានរាយការណ៍កាលពីថ្ងៃអង្គារថា សហរដ្ឋអាមេរិកកំពុងតស៊ូដើម្បីបន្តកិច្ចសន្ទនាយោធា និងយោធាជាមួយប្រទេសចិនជាច្រើនខែបន្ទាប់ពីកិច្ចប្រជុំរវាងប្រមុខរដ្ឋលោក Joe Biden និងលោក Xi Jinping។

ទីក្រុងប៉េកាំង បានច្រានចោលការប៉ុនប៉ងរបស់ក្រសួងការពារជាតិអាមេរិកដើម្បីចូលរួមក្នុងបញ្ហាសន្តិសុខដែលមានសារៈសំខាន់ដើម្បីជៀសវាងវិបត្តិដែលអាចកើតមានរវាងសហរដ្ឋអាមេរិក និងចិននេះបើយោងតាមការលើកឡើងរបស់មន្ត្រីការពារជាតិជាន់ខ្ពស់របស់សហរដ្ឋអាមេរិក។

ទំនាក់ទំនងរវាងប្រទេសទាំងពីរ បានផ្អាកបន្ទាប់ពីដំណើរទស្សនកិច្ចកាលពីខែសីហា ដោយអតីតប្រធានសភាអាមេរិក Nancy Pelosi ទៅកាន់កោះតៃវ៉ាន់ ទោះបីជាមានការតវ៉ាពីទីក្រុងប៉េកាំងក៏ដោយ។

កាលពីខែវិច្ឆិកា លោក Biden និងលោក Xi បានជួបគ្នានៅខាងក្រៅកិច្ចប្រជុំ G20 នៅប្រទេសឥណ្ឌូនេស៊ី ហើយបានពិភាក្សាអំពីស្ថានភាពទាក់ទងនឹងច្រកសមុទ្រតៃវ៉ាន់។

ក្រោយមកក្នុងខែវិច្ឆិកា រដ្ឋមន្ត្រីការពារជាតិអាមេរិក លោក Lloyd Austin បានជួបជាមួយរដ្ឋមន្ត្រីក្រសួងការពារជាតិចិន លោក Wei Fenghe នៅកម្ពុជា ដើម្បីពិភាក្សាអំពីទំនាក់ទំនងការពារជាតិរវាងសហរដ្ឋអាមេរិក និងចិន បញ្ជៀសនិស្សុខក្នុងតំបន់ និងពិភពលោក។

លោក Austin បានសង្កត់ធ្ងន់លើតម្រូវការសម្រាប់ទំនាក់ទំនងបើកចំហររវាងសហរដ្ឋអាមេរិក និងប្រទេសចិន។ របាយការណ៍បាននិយាយថា ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីពេលនោះមកទីក្រុងប៉េកាំងបានបដិសេធការប៉ុនប៉ងរបស់ទីក្រុងវ៉ាស៊ីនតោន ដើម្បីបង្កើតបណ្តាញទំនាក់ទំនងធម្មតាសម្រាប់បញ្ហាការពារជាតិ។

របាយការណ៍បានបន្ថែមថា យោធាចិនក៏បានធ្វើសកម្មភាពដោយមិនប្រុងប្រយ័ត្នចំពោះកងកម្លាំងអាមេរិកនៅក្នុងសមុទ្រចិនខាងត្បូង ចាប់តាំងពីទំនាក់ទំនងនេះត្រូវបានបែកបាក់៕

ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

# ការសិក្សាស្រាវជ្រាវសាគរសាស្ត្រ និងធនធានជលផល នៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣-១៩៨៦ (ត)

## ៥.១.២ លក្ខខណ្ឌឧតុនិយម

ឈូងសមុទ្រថៃ (ក៏មានសមុទ្រកម្ពុជាដែរ) ស្ថិតនៅក្នុងតំបន់ក្រោមខ្សែបន្ទាត់អេក្វាទ័រ (sub-equatorial) ដែលរងឥទ្ធិពលពីខ្យល់មូសុង។ ការផ្លាស់ប្តូរថាមពលត្រូវបានបង្ករឡើងតាមសីតុណ្ហភាពខុសប្លែកគ្នារវាងម៉ាស់ខ្យល់អាកាសនៅពីលើសមុទ្រ និងទ្វីប។ នៅរដូវប្រាំងខ្យល់អាកាសនៃទ្វីបនៅអាស៊ីក្តៅជាងខ្យល់អាកាសនៅសមុទ្រ តែវាផ្ទុយគ្នាទាំងស្រុងនៅរដូវរងា។ការកើនឡើងនៃសីតុណ្ហភាពម៉ាស់ខ្យល់អាកាសនៅអាស៊ីបានបង្កើតជាតំបន់ដែលមានសម្ពាធទាប និងប្រព័ន្ធខ្យល់មូសុង តែនៅរដូវរងាគឺផ្ទុយគ្នាទាំងស្រុង។

នៅអំឡុងខែកុម្ភៈ-មេសា ខ្យល់ភាគច្រើនបក់ពីត្បូងឈៀងកើត និងពីត្បូងនៅលើផ្ទៃទឹកនៃសមុទ្រកម្ពុជា។ នៅខែឧសភា នៅពេលដែលខ្យល់ប្តូរទិសរបបខ្យល់ត្រូវបាត់បង់ស្ថេរភាព ឯខ្យល់ពីលិច និងពីត្បូងឈៀងកើត មានតិចតួចបំផុត។ នៅអំឡុងខែមិថុនាដល់១៥ថ្ងៃដំបូងនៃខែតុលា ខ្យល់ភាគច្រើនបំផុតបក់ពីលិច និងត្បូងឈៀងលិច។ នៅខែតុលាខ្យល់មូសុងបានប្តូរទិស។ ចាប់ពីពាក់កណ្តាលខែតុលាដល់ខែធ្នូ ខ្យល់ភាគច្រើនបក់ពីខាងកើតនិងពីខាង ជើងឈៀងកើតជាញឹកញាប់។ ពេលដែលអត់ខ្យល់សោះ (death time) តែងតែប្រទះឃើញភាគច្រើនៅខែឧសភា និងនៅអំឡុងខែកញ្ញា-តុលា (តារាងលេខ១)។

តារាង២. ចលនាខ្យល់ដែលមានឥទ្ធិពលលើតំបន់ស្រាវជ្រាវនៃសមុទ្រកម្ពុជា

| ដំណាក់កាលនៃការអង្កេត | ទិសនិងភាពញឹកញាប់នៃខ្យល់ | ភាពញឹកញាប់នៃពេលអត់ខ្យល់(%) |
|---|---|---|
| មករា - កុម្ភៈ | ត្បូង (២៦%); ត្បូងឈៀងកើត (៣៦%) | ៩ |
| មិនា - មេសា | ត្បូង (១៨%); ត្បូងឈៀងកើត (៣៤%) | ១៩ |
| ឧសភា | ត្បូងឈៀងលិច (១៧%); ត្បូង (១៦%) ); កើត (១៣%); ត្បូង ឈៀងកើត (៣៦%); លិច (១១%) ); ត្បូងឈៀងកើត (១១%) | ២៦ |
| មិថុនា | លិច(៤៥%) ); កើត (២៣%) | ២ |
| កក្កដា | លិច និងត្បូងឈៀងលិច (៧៥%) | ១៥ |
| កញ្ញា-ពាក់កណ្តាលខែតុលា | ជើងឈៀងលិច (១១%); លិច (២៣%); ត្បូង (១៥%) | ៣៨ |
| ពាក់កណ្តាលទី២ខែតុលា-វិច្ឆិកា | កើត (២២%); ជើងឈៀងកើត (១៥%) | ២៤ |
| ធ្នូ | ជើងឈៀងកើត (២៤%) ); ជើង (២៨%) ); កើត (២២%) | ២២ |

កំណត់សម្គាល់: ទិន្នន័យខាងលើទទួលបានពីការបូកសរុបការអង្កេតវិភាគប្រចាំថ្ងៃ (៤ដង/ថ្ងៃ) ដោយនាវាស្រាវជ្រាវទាំងអស់ដែលបានមកធ្វើការអង្កេតនៅសមុទ្រកម្ពុជាក្នុងអំឡុងឆ្នាំ១៩៨៣-៨៦។

## ៥.២ លក្ខខណ្ឌសាគរសាស្ត្រ

### ៥.២.១ ចរន្តទឹក

ចរន្តទឹកក្នុងតំបន់ស្រាវជ្រាវនៃសមុទ្រកម្ពុជា កើតឡើងពីមូលដ្ឋាននៃអន្តរកម្មរួមនៃខ្យល់លំហូរស្ទឹង ទន្លេស្ថានភាពបាតសមុទ្រនិងភាពខាប់ខុសៗគ្នាដែលមាននៅក្នុងតំបន់ផ្សេងៗនៃសមុទ្រ។ នៅក្នុងតំបន់ស្រាវជ្រាវនេះ ចរន្តទឹកត្រូវបានគណនាពីទិន្នន័យសីតុណ្ហភាពនិងកំហាប់អំបិលនៃទឹកសមុទ្រដែលប្រែប្រួលខុសៗគ្នាទៅតាមជំរៅទឹក។ នៅផ្ទៃខាងលើ ចរន្តទឹករងឥទ្ធិពលពីព្យុះស៊ីក្លូននៅចុងរដូវរំហើយ (មករា-កុម្ភៈ)ដែលចរន្តទឹកបត់បែនជាភ្នែនហូរចេញទៅភាគខាងជើងឈៀងលិច។ នៅរដូវប្រាំង (មេសា-ឧសភា)ចរន្តទឹកចិតនៅក្រោមឥទ្ធិពលចរន្តមេ នៅភាគខាងលិចដែលមានលក្ខណៈគួចវិលវល់បត់បែនដោយព្យុះស៊ីក្លូនដែលមានវិជ្ជមាត្រដល់ ៦០ ម៉ែល៍។ នៅដើមរដូវវស្សា (មិថុនា-កក្កដា) ចរន្តទឹកមានការប្រែប្រួលយ៉ាងខ្លាំងដោយឥទ្ធិពលខ្យល់ម៉ូសុងពីត្បូងនិងពីលិចដែលជាទូទៅរងឥទ្ធិពលពីចរន្តមួយដែលហូរនាំទៅទិសខាងជើង។នៅភាគខាងត្បូងឈៀងលិច ចរន្តទឹកបត់បែនជាភ្នែន ហូរទៅ ទិសខាងលិច។ នៅចុងរដូវវស្សា ចរន្តទឹកនៅផ្ទៃលើរក្សាស្ថានភាពដដែល។នៅខាងជើងកោះ តាងចរន្តទឹកហូរទៅ ទិសខាងជើងឈៀងលិច។ មួយភាគធំនៃតំបន់ ចរន្តទឹកមាននិន្នាកាហូរទៅទិសខាងត្បូង ក្នុងនោះក៏មានទឹកគួចវិលវល់ដោយព្យុះស៊ីក្លូនខ្លះៗដាច់ៗពីគ្នាជាពិសេសមានទឹកគួចវិលវល់ដោយព្យុះស៊ីក្លូនចំនួនបីបានករកើតឡើងនៅភាគខាងលិច។

### ៥.២.២ សីតុណ្ហភាពទឹក

តំបន់ស្រាវជ្រាវឋិតក្នុងតំបន់អេក្វាទ័រក្តៅដែលស្រទាប់លើនៃទឹកមានសីតុណ្ហភាពជាអតិបរិមា។ ដោយសាររបបកម្តៅនេះ ទឹកសមុទ្រនៅឈូងសមុទ្រថៃ ដែលសមុទ្រកម្ពុជានៅខាងក្នុងដែរនោះ ត្រូវបានចាត់ទុកជាប្រភេទត្រូពីក-អេក្វាតូរីយ៉ាលដែលបង្ហាញលក្ខណៈតាមការប្រែប្រួលតិចតួចតាមរដូវ ក្នុងកំរិត ២,៥០អង្សាសេប៉ុណ្ណោះហើយសីតុណ្ហភាពមធ្យមនៅផ្ទៃលើទឹកស្មើរនឹង២៨,៥០អង្សាសេ។

**-នៅអំឡុងខែធ្នូ** សីតុណ្ហភាពនៅផ្ទៃលើទឹកប្រែប្រួលពី ២៧០អង្សាសេ នៅម៉្តុំកោះព្រីង ទៅដល់ ៣០,៥០អង្សាសេ នៅតំបន់ខាងជើងឈៀងលិច និង មាន ២៩០-២៩,៥០អង្សាសេ នៅតំបន់ក្បែរឆ្នេរ។ ចាប់ពីជំរៅ ៥០ម ឡើងទៅ ទឹកមានភាពត្រជាក់។

**-នៅអំឡុងខែកុម្ភៈ** សីតុណ្ហភាពផ្ទៃលើទឹកប្រែប្រួលក្នុងកំរិត ១,៤០អង្សាសេ។ សីតុណ្ហភាពអតិបរិមាត្រូវបានប្រទះឃើញនៅភាគខាងជើងឈៀងលិចនៃកោះព្រីង ដែលប្រសព្វគ្នាជាមួយចំណុចកណ្តាលនៃចលនាព្យុះស៊ីក្លូន។ សីតុណ្ហភាពកើនឡើងនៃទឹកនៅតំបន់នេះ ត្រូវបានសង្កេតឃើញរហូតដល់ជំរៅ២០ម ជាកន្លែងដែលអាចប្រៀបធៀបបានជាមួយស្រទាប់លើ។ ចំណុចទឹកក្តៅបានប្តូរទីតាំងទៅភាគខាងត្បូង។ នៅតំបន់ទឹកជ្រៅសីតុណ្ហ-ភាពអតិបរិមានៅផ្ទៃលើមាន២៨,៣០អង្សាសេ និង នៅជិតស្រទាប់បាតមាន២៨,២០អង្សាសេ។ នៅព្រំប្រទល់ភាគខាងលិច សីតុណ្ហភាពប្រែប្រួលចាប់ពី ២៧,១០ អង្សាសេ នៅផ្ទៃលើ ទៅ២៧,៥០អង្សាសេ នៅជិតស្រទាប់បាត។ នៅកន្លែងផ្សេងទៀត សីតុណ្ហ-ភាពស្រទាប់បាតមានស្មើនឹង ២៧,៧៥០អង្សាសេ។

**-នៅអំឡុងខែមេសា** សីតុណ្ហភាពផ្ទៃលើទឹកកើនឡើងជាមធ្យម ១,៥០អង្សាសេ បើប្រៀបធៀបទៅនឹងខែកុម្ភៈ។សីតុណ្ហភាពអតិបរិមាផ្ទៃលើទឹកនៅតំបន់ទឹកជ្រៅមាន៣០,១០អង្សាសេ។ សីតុណ្ហភាពទឹកពីផ្ទៃ លើដល់បាត មានភាពលំអៀងតិចតួច ដែលក្នុងនោះសីតុណ្ហភាពនៅស្រទាប់បាត ប្រែប្រួលពី ២៧០ អង្សាសេ នៅភាគខាងត្បូងដល់ទៅ ២៩,៥០ អង្សាសេនៅតំបន់ក្បែរច្រាំង។សីតុណ្ហភាពអតិបរិមានៅភាគខាងត្បូង ធ្លាក់ចុះដល់ ២៦,៧០អង្សាសេ នៅពេលទឹកមកពីសមុទ្រខាងត្បូងចូលមកដល់។

**-នៅខែឧសភា** សីតុណ្ហភាពផ្ទៃលើទឹកកើនឡើងដល់២៩,៧០អង្សាសេ។ នៅក្នុងភាគខាងជើង

ឈៀងលិច សីតុណ្ហភាពទឹក ពីផ្ទៃលើដល់បាតរហូតដល់តំបន់ជំរៅ៣០ម៉ែត្រ និងនៅភាគខាងត្បូងពីផ្ទៃលើដល់បាតរហូតដល់តំបន់ជំរៅ១០ម៉ែត្រ មានប្រហាក់ប្រហែលគ្នា។ សីតុណ្ហភាពទឹកនៅស្រទាប់បាតប្រែប្រួលពី២៧,៥០អង្សាសេនៅតំបន់ខាងត្បូងទៅ៣០,០០អង្សាសេនៅតំបន់ជិតខាងច្រាំងដែលមានន័យថា របាយសីតុណ្ហភាព វាអាស្រ័យទៅតាមខ្សែបន្ទាត់ជំរៅទឹកសមុទ្រ។

**-នៅខែមិថុនា** មានការប្រែប្រួលយ៉ាងសកម្មដោយខ្យល់ដែលធ្វើឲ្យសីតុណ្ហភាពទឹកសមុទ្រផ្ទៃលើធ្លាក់ចុះ ជាមធ្យម ១,៥០អង្សាសេ បើប្រៀបធៀបទៅនឹងខែឧសភា។ ជាទូទៅសីតុណ្ហភាពប្រែប្រួលពី២៩,២០ អង្សាសេនៅផ្ទៃលើ ទៅ២៧,៦០អង្សាសេនៅស្រទាប់បាត។

**-នៅខែកក្កដា**សីតុណ្ហភាពនៅស្រទាប់លើទឹកប្រែប្រួលពី២៩,៧០អង្សាសេនៅភាគខាងជើងឈៀងលិចទៅ២៨,៧៥០អង្សាសេនៅតំបន់ក្បែរច្រាំង។ទឹកនៅភាគខាងជើងឈៀងលិច បានបង្ហាញពីសីតុណ្ហភាព ដែលកើនឡើងខ្ពស់តាំងពីផ្ទៃលើដល់ស្រទាប់បាត។ការសាយភាយនៃទឹកក្តៅថិតនៅពីលើស្រទាប់បាត នៅចន្លោះខ្សែជំរៅទឹក៧០-៦០ម៉ែត្រ។ សីតុណ្ហ-ភាពអតិបរិមានៅស្រទាប់បាតមាន២៩,៤០អង្សាសេត្រូវបានកត់ត្រានៅភាគខាងកើតឈៀងត្បូងនៅក្នុងចន្លោះខ្សែជំរៅទឹក៤០-៥០ម៉ែត្រ។ សីតុណ្ហភាពអតិបរិមានៅជាប់បាតសមុទ្រមាន២៨៣០អង្សាសេបានកត់ត្រានៅទីជំរៅ៦០ម៉ែត្រនៅភាគខាងជើង។ សីតុណ្ហភាពទឹកមានចាប់ពី២៨,៥០ ទៅ ២៨,៧៥០ អង្សាសេ នៅបាតសមុទ្រជំរៅ៧០ម៉ែត្រ។

**-នៅអំឡុងខែកញ្ញា-តុលា**របាយសីតុណ្ហ-ភាពនៅផ្ទៃលើទឹកនៅពេលនេះមានលក្ខណៈជាលំអានដោយដុំ។ ការប្រែប្រួលសីតុណ្ហភាពនៅស្រទាប់លើមានមិនលើសពី០៥០អង្សាសេឡើយ។ដោយសារតែមានការជ្រៀតចូលនៃទឹកត្រជាក់មកពីភាគខាងត្បូងនៃឈូងសមុទ្រថៃ សីតុណ្ហភាពទឹកបានធ្លាក់ចុះពី០,៥០ ទៅ២,៥០អង្សាសេនៅតំបន់ចាប់ពីខ្សែជំរៅទឹក៥០ម៉ែត្រឡើងទៅ។ បើប្រៀបធៀបរបាយសីតុណ្ហភាពនៅផ្ទៃលើទឹកតាមក្រិតផ្ដេកសីតុណ្ហភាពបានកើនឡើងយ៉ាងគំហុក ចាប់ពីតំបន់នៃខ្សែជំរៅទឹក៥០ម៉ែត្រឡើងទៅ ក្នុងកំរិត០,៣០អង្សាសេក្នុងរយៈមួយម៉ែល៍ឡើងទៅ។

### ៥.២.៣ កំហាប់អំបិល

ការប្រែប្រួលតាមរដូវនៃកំហាប់អំបិល នៃទឹកសមុទ្រកម្ពុជាវាអាស្រ័យទៅតាមបម្រែបម្រួលនៃនៃភ្លៀងធ្លាក់តាមឆ្នាំ និងការហូរចូលនៃទឹកស្ទឹងទន្លេប្រចាំឆ្នាំផងដែរ។បម្រែបម្រួលតាមរដូវនៃកំហាប់អំបិលនៅស្រទាប់លើនៃតំបន់ ត្រូវថិតនៅក្នុងចន្លោះ២៨-៣២,២៣‰ នៅតំបន់ក្បែរច្រាំង និងនៅក្នុងចន្លោះ៣០,៥-៣២,០‰ នៅលំហរសមុទ្រ។

អត្រាកំហាប់អំបិលនៅស្រទាប់លើប្រែប្រួលនៅក្រោមឥទ្ធិពលនៃការមកដល់នៃទឹកដែលកំហាប់អំបិលទាប មកពីឆ្នេរខាងជើង និងទឹកដែលមានកំហាប់អំបិលខ្ពស់ នៃភាគខាងត្បូងដ៏ធំនៃឈូងសមុទ្រថៃ។ ស្រទាប់លើទឹកក៏បានទទួលផងដែរ នូវទឹកសាបដោយផ្ទាល់នៅក្នុងតំបន់នៅពេលមានភ្លៀងគ្រូពិក។

**-នៅអំឡុងខែធ្នូ-កុម្ភៈ** ដោយសារតែមានការធ្លាក់ចុះនៃលំហូរទឹកសាបពីស្ទឹងទន្លេនោះ កំហាប់អំបិលបាន នៅតំបន់ក្បែរច្រាំងបានកើនឡើងដល់៣២,២៥‰ ដែលកាលពីខែវស្សាវាមានបានធ្លាក់ចុះដល់២៨‰។ព្រមៗគ្នានោះដែរនៅរដូវប្រាំងនៅភាគខាងត្បូងនៃតំបន់ដែលស្រាវជ្រាវការមកដល់នៃទឹកពីភាគខាងត្បូងក្រោមឥទ្ធិពលនៃខ្យល់ម៉ូសុងទិសខាងត្បូងឈៀងលិច ដែលធ្វើឲ្យទឹកស្រទាប់លើមានកំហាប់អំបិល ឡើងដល់៣៣‰។ នៅខែធ្នូកំហាប់អំបិលនៅស្រទាប់លើប្រែប្រួលពី ៣០,៥‰ ដល់២៩,៥‰។ ទឹកដែលមានកំហាប់អំបិលខ្ពស់មានវិសាលភាពធំនៅក្នុងសមុទ្រទាំងមូល។ ជំរៅទឹកប៉ុណ្ណា កំហាប់អំបិលក៏កើនឡើងតាមនោះ ក្នុងទម្រង់

៣២,៥‰ យ៉ាងទៀងទាត់ នៅស្រទាប់ជាប់នឹងបាតសមុទ្រ។ ទិន្នន័យនេះ បង្ហាញថាលំដាប់ថ្នាក់បញ្ឈរ អតិបរិមា នៃកំហាប់អំបិលកើនឡើងនៅស្រទាប់ទឹកជាប់បាតសមុទ្រនៅកន្លែងដែលជ្រៅ។ នៅខែកុម្ភៈ កំហាប់អំបិលនៅផ្ទៃលើទឹក បានកើនឡើងជាមធ្យម ២‰។ តំបន់ដែលមានកំហាប់អំបិលខ្ពស់ចន្លោះពី (៣១,៧៥-៣២,២៥‰)ត្រូវបានប្រទះឃើញនៅភាគខាងកើតនៃតំបន់ស្រាវជ្រាវ។ កំរិតកំហាប់អំបិលអតិបរិមាត្រូវប្រទះឃើញនៅក្បែរច្រាំងនិងភាគខាងជើងឈៀងលិចនៃកោះព្រីង។ នៅខែនេះជាសំខាន់ គឺ គ្មានភ្លៀងធ្លាក់ ឯលំហូរទឹកសាបពីស្ទឹងទន្លេក៏មិនច្រើនដែរ ព្រមជាមួយកំរិតសីតុណ្ហភាព និង អាកាសធាតុដែលរក្សាកំរិតខ្ពស់ផងនោះបានបង្ករឲ្យមានរំហួតស្រទាប់លើទឹកយ៉ាងខ្លាំង ដែលធ្វើឲ្យកំហាប់អំបិលកើនឡើងច្រើន។ចំណុចនៃទឹកដែលមានកំហាប់អំបិលខ្ពស់នៅតំបន់កណ្ដាល នៃផ្ទៃ សមុទ្រ វាស្របគ្នាជាមួយសីតុណ្ហភាពអតិបរិមាដាច់ខាតនៃផ្ទៃលើទឹក។ នៅកន្លែងដែលមានកំហាប់អំបិលទាបនៅភាគខាងលិចនៃតំបន់នោះគឺដោយសារមានលំហូរទឹកចូលនៃទឹកដែលមានកំហាប់អំបិលទាបមកពីភាគខាងជើងនៃឈូងសមុទ្រថៃ។ ជាទូទៅកំហាប់អំបិលកើនឡើងទៅតាមជំរៅទឹក។គេសង្កេតឃើញស្រទាប់ទឹកជាប់បាតសមុទ្រ មានសភាពដូចគ្នា ដែលកំរិតកំហាប់អំបិលប្រែប្រួលនៅក្នុងចន្លោះ ៣២,២៥‰ នៅទីជំរៅ រហូតដល់ចន្លោះ ៣៣-៣៣,៣៣‰ នៅភាគខាងលិចនៃតំបន់។ កំហាប់អំបិល អតិបរិមានៃទឹកស្រទាប់បាត ត្រូវបានប្រទះឃើញនៅក្នុងឆកកំពង់សោម។

**-នៅអំឡុងខែមេសា-ឧសភា** របាយកំហាប់អំបិលនៅផ្ទៃលើទឹកមានលក្ខណៈប្រមូលផ្ដុំចំពីគ្នាជាមួយការប្រែប្រួលក្នុងកំរិតពី៣១,៨-៣៣,០‰ដែលក្នុងនោះកំហាប់អំបិលអតិបរិមា (៣១,៨‰) ប្រទះឃើញនៅស្រទាប់លើនៃតំបន់កោះកណ្ដាលនិងកោះស្មិត និង (៣៣,០‰) នៅព្រំដែនខាងជើងនៃតំបន់សិក្សា ជាពិសេសនៅខែមេសា។ ថាមពលដែលស្ទើរតែដូចគ្នានៃស្រទាប់លើទឹក នៃតំបន់សិក្សាទាំងមូលមានការប្រែប្រួលពីជំរៅ ៣០ទៅ៥០ម៉ែត្រ រីឯកំហាប់អំបិលក៏ប្រែប្រួលពី៣២,៣‰ទៅ៣២,៨‰ដែរហើយជាមួយគ្នានឹងការកើនឡើងនៃជំរៅនេះដែរកំហាប់អំបិលក៏កើនឡើងដូចគ្នាជាសន្សឹមៗផងដែរ។ កំរិតកំហាប់អំបិល នៅស្រទាប់បាតកើនលើសស្រទាប់លើជាមធ្យមចំនួន១‰។ កំហាប់អំបិលអតិបរិមា (៣៣,៨‰) នៅស្រទាប់ទឹកជាប់បាតសមុទ្រត្រូវបានប្រទះឃើញនៅព្រំដែនភាគខាងត្បូងនៃតំបន់ ដែលជាកន្លែងដែលទឹកមកពីសមុទ្រចិនខាងត្បូងហូរចូលមកដល់។ របាយកំហាប់អំបិលស្រទាប់លើទឹកនៃសមុទ្រកម្ពុជានៅ ខែឧសភាជាសក្ខីភាពនៃការចាប់ផ្ដើមនៃរដូវវស្សា។រដូវនេះត្រូវបានបញ្ជាក់តាមការធ្លាក់ចុះនូវកំហាប់អំបិលនៅតំបន់ជិតខាងឆ្នេរក្រោមឥទ្ធិពលទឹកសាបពីដីគោក។ កំរិតកំហាប់អំបិលនៅអំឡុងខែនេះ នៅទឹកតំបន់ឆ្នេរប្រែប្រួលពី ៣១,៣‰ ទៅ៣២,២‰ ដែលតាមរយៈនេះគេអាចមើលឃើញទីលានរងឥទ្ធិពលកំហាប់អំបិលយ៉ាងច្បាស់នៃព្រំដែនឆ្នេរសមុទ្រ។ ការថយចុះនៃខ្យល់ម៉ូសុងនិរតីនៅខែឧសភាបានធ្វើឲ្យមានការចូលមកដល់នូវទឹកដែលបង្ករដោយចរន្តដែលបែកខ្វែកក្នុងតំបន់សិក្សានៅភាគខាងត្បូងនៃឈូងសមុទ្រថៃ។ វាបង្ហាញថា នៅភាគខាងត្បូងនៃតំបន់សិក្សាត្រូវបានសម្គាល់ឃើញតំបន់ដែលមានកំហាប់អំបិលខ្ពស់ខ្លាំងចាប់ពីស្រទាប់ទឹក ០ ដល់ ៥០ម៉ែត្រ។ មួយភាគធំនៃតំបន់មានស្រទាប់ស្ទើរតែដូចគ្នា នៅផ្ទៃលើទឹកដែលថាមពលក្នុងចន្លោះតំបន់ជំរៅពៅ២០ទៅ៣០មែត្រ កំហាប់អំបិលមធ្យមមាន៣២.២‰។ ផ្ទុយពីរដូវរំហើយ នៅខែឧសភានេះនៅភាគនារតីនៃតំបន់ គេមិនដែលបានឃើញស្រទាប់បាត ជាមួយក្រិតបញ្ឈរនៃកំហាប់អំបិលកើនឡើងនៅចន្លោះជំរៅពី ២០ ទៅ ៣០ម៉ែត្រឡើយ។តួលេខនេះបញ្ជាក់តាមការស្ទង់ថាតំបន់នេះ មានទឹកដែលមានកំហាប់អំបិល ៣៣,៦-

៣៣,៧‰។នៅភាគខាងជើងនៃតំបន់កំហាប់អំបិលនៃទឹកនៅស្រទាប់បាត ជំរៅចាប់ពី៦០ទៅ៧០ម៉ែត្រ មានមិនលើសពី៣៣,២‰ ឡើយ។

**-នៅខែមិថុនា** ផ្ទៃនៃស្រទាប់ទឹកមិនសូវប្រែខាងលើបានបង្កើនវិសាលភាពបើប្រៀបធៀបនឹងងខែឧសភា។ នៅក្បែរច្រាំងកំហាប់អំបិលមាន ៣១,៤‰ ឯនៅភាគខាងត្បូងងាចឈានដល់៣៣‰។ នៅភាគខាងជើងឈៀងលិចទឹកមានកំហាប់អំបិលទាប ហើយនៅទីតាំងនៃតំបន់ជំរៅទឹក៥០ម៉ែត្រ នៃភាគកណ្តាលនៃតំបន់បានបង្ហាញតំបន់ខណ្ឌចែកទឹកប្រែខ្លាំងដែលមកពីភាគខាងត្បូងនៃឈូងសមុទ្រថៃនិងទឹកមិនសូវប្រែមកពីឆ្នេរ។ក្រិតផ្ចេកនៃកំហាប់អំបិលបង្ហាញព្រំដែននៃកំរិតប្រែនៃទឹកមានដល់ ០,៤‰ ក្នុងរវាងចម្ងាយ ១០ម៉ៃល៍ម្តង។ ដូចជានៅក្នុងខែ ឧសភា នៅក្នុងផ្នែកខាងឆ្នេរសមុទ្រនៃតំបន់ទឹកត្រូវបានលាយជាមួយទឹកសាបចាប់ពីស្រទាប់លើដល់ស្រទាប់បាត ហើយជាងនេះទៅទៀតទឹកលាយគ្នានេះបានលាតរហូតទៅ ដល់ទីជំរៅទឹក៣០-៤០មែត្រ។ នៅស្រទាប់ទឹកលាយគ្នានេះ ជាក់ស្តែង កំហាប់អំបិលមិនអាស្រ័យទៅតាមជំរៅឡើយ។

**-នៅអំឡុងខែកក្កដា** កំហាប់អំបិលនៃទឹកស្រទាប់លើនៅលើមួយភាគធំនៃតំបន់ស្រាវជ្រាវបានប្រែប្រួលតិចតួចពី ៣២‰នៅម្តុំកោះព្រីង កោះរ៉ៃនិងកោះតាង ទៅដល់ ៣២,៥‰ នៅភាគខាងលិចនៃតំបន់។ ក្នុងតំបន់ទឹកជ្រៅនៅភាគខាងលិចនៃតំបន់ស្រាវជ្រាវ កំហាប់អំបិលបានថយចុះដក់២៨‰។ ជាទូទៅនៅ ផ្នែកជាប់ជិតឆ្នេរ កំហាប់អំបិលបានថយចុះ១‰។ការរីកសាយនៃតំបន់ទឹកមិនសូវប្រែត្រូវបានកំណត់ ដោយខ្សែជំរៅទឹក៣២‰ ដែលកំហាប់អំបិលអតិបរិមាក្នុងតំបន់ឆកកោះកុងមាន២៧,៤‰ នៅក្នុងតំបន់ឆកកំពង់សោមមាន២៩,៧‰។ឥទ្ធិពលនៃទឹកមិនសូវប្រែបានជ្រៀតទៅដល់ជំរៅ ១០ ទៅ ២០ម៉ែត្រ។នៅក្នុងតំបន់ដែលទឹកមិនសូវប្រែមកពីឆកនានាចូលមកដល់ក្រិតផ្ចេកនៃកំហាប់អំបិលបានកើនឡើងគួរឲ្យចាប់អារម្មណ៍ ដោយនៅក្បែរឆកកោះកុងបានកើនដល់៣,១‰ សម្រាប់រយៈចម្ងាយ១០ម៉ៃល៍ ហើយនៅក្នុងឆកកំពង់សោម កើនឡើង ១,៨‰ សម្រាប់រយៈចម្ងាយ១០ម៉ៃល៍ ដែលទន្ទឹមគ្នានេះដែរ ក្រិតបញ្ឈរនៃកំហាប់អំបិលក៏ត្រូវបានគេមើលឃើញដូចគ្នាដែរនៅតំបន់ទាំងនោះ។ ភាគច្រើននៃតំបន់ ជាពិសេស ចាប់ពីជំរៅ ៣៥ម៉ែត្រឡើងទៅ ស្រទាប់លើទឹកមានលក្ខណៈជារបាយកំហាប់អំបិលដូចគ្នា។ ក្រិតបញ្ឈរនៃកំហាប់អំបិលប្រែប្រួលពី០,០៥‰ទៅ ០,១០‰ ក្នុងរយៈ១ម៉ែត្រចាប់ពីផ្ទៃលើទឹកចុះដល់បាតសមុទ្រ។ កំហាប់អំបិលអតិបរិមានៅជិតបាតសមុទ្រកើនដល់៣៣,៨‰នៅភាគខាងត្បូងឈៀងលិចនៃតំបន់។ កំហាប់អំបិលបានថយចុះនៅជិតស្រទាប់បាតនៅភាគកណ្តាល នៃតំបន់ស្រាវជ្រាវបង្ករដោយទឹកដែលរងឥទ្ធិពលពីទឹកគួចប្រឆាំងព្យុះស៊ីក្លូន។ នៅជិតច្រាំងកំហាប់អំបិលថយចុះដល់ ៣២,៣‰-៣២,៥‰ នៅក្នុងឈូងសមុទ្រថៃ និងចុះដល់៣១,៦២‰ នៅតំបន់កោះត្រល់។

**-នៅអំឡុងខែកញ្ញា-តុលា** ក្នុងដំណាក់កាលនេះកំហាប់អំបិលនៅផ្ទៃលើទឹកត្រូវរងឥទ្ធិពលភ្លៀងខ្យល់ជាញឹកញាប់ នៅពីខាងលើផែនទឹកនៃតំបន់។ ប្រៀបធៀបជាមួយរដូវប្រាំងកំហាប់អំបិលនៅផ្ទៃលើទឹកនៃតំបន់សិក្សាបានធ្លាក់ចុះពី១-២‰។ គេអាចកំណត់តំបន់ព្រំប្រទល់តាមលក្ខណៈនៃតំបន់ទឹកមិនសូវប្រែ និងតំបន់ទឹកប្រែខ្លាំងនៅលំហរសមុទ្រ លើកលែងតែតំបន់ក្បែរច្រាំងនៃតំបន់ដែលនៅទីនោះ កំហាប់អំបិល ចាប់ពីផ្ទៃលើទឹកទៅដល់បាតមិនប្រែប្រួលខ្លាំងក្លាទេ។ ដូច្នេះនៅទូទាំងឆ្នាំ ភាពច្រំដែលៗនៃកំហាប់អំបិលមានការប្រែប្រួលជាច្រើនដង។ នៅរដូវវស្សា (ខែឧសភា-តុលា) អតិក្រមនៃការធ្លាក់ចុះកំហាប់អំបិលនៃទឹកនៅក្បែរច្រាំងលេចចេញពីលំហូរទឹកសាបពីដីគោកដែលធ្វើឲ្យមានការករកើតនៅក្បែរច្រាំងនៃតំបន់ដែលក្រិតផ្ចេក កើនឡើងនៃកំហាប់អំបិល ដែលប្តូរចេញជាបន្តរបន្ទាប់ទៅភាគខាងលិច

ពេញមួយរដូវ។ ខ្យល់ត្រូពិចជាទូទៅ ត្រូវបានជម្រុញកម្លាំងដោយខ្យល់ ដែលធ្វើឲ្យមានការលាយម៉ាស់នៃទឹកនៃឈូងសមុទ្រថៃ។ ជាក់ស្តែងនៅក្នុងរដូវវស្សា គ្រប់ស្រទាប់ទឹកទាំងអស់ចាប់ពីផ្ទៃលើដល់បាត សុទ្ធតែមានកំហាប់អំបិលដូចគ្នានៅភាគកណ្តាល និងភាគខាងលិច។ នៅពេលរដូវវស្សាបានបញ្ចប់ ទៅនោះ ម៉ាស់ទឹកនៃឈូងសមុទ្រថៃក្លាយជាចំណាត់ថ្នាក់នៃកំហាប់អំបិលកើនឡើងទៅតាមជំរៅទឹក។

## ៥.២.៤ វត្ថុធាតុនៃជីវពន្ធ (Biogene)

សារធាតុហ្វូសហ្វ័រ (Phosphorus) និងសមាសភាគ ឬធាតុផ្សំរបស់វា ជាផ្នែកនៃរាល់ការបង្កើតកោសិកាទាំងអស់ ដោយសម្រួលអភិក្រមសំខាន់ជាសារវន្តៈ រស្មីសំយោគ(photosynthesis) ការដកដង្ហើម (respiration) ការដុតរំលាយអាហារក្នុងរាងកាយ (metabolism) និងអ្វីផ្សេងទៀត។ សារធាតុស៊ីលីស្យូម (silicium) បានដើរតួយ៉ាងសំខាន់ក្នុងអភិក្រមជីវនៅបរិស្ថានមហាសាគរដែលជាផ្នែកនៃការបង្កើតគ្រោងឆ្អឹងសត្វសមុទ្រ។ របាយវត្ថុធាតុជីវពន្ធក្នុងទឹកសមុទ្រកំណត់ផលិតភាពជីវក្នុងតំបន់ និងធនធានជាចំណីសម្រាប់ត្រី ទោះជាអត្រាហ្វូសហ្វាតក្នុងទឹកសមុទ្រ នៅក្រោមលក្ខខណ្ឌខ្លះៗជាកត្តាកំហិតនៃចំនួនប្រភេទហ្វីតូប្លង់តុងក៏ដោយ។ ខនិជភាវូប្បនីយកម្ម (mineralization) នៃកំទិចកំទីសរីរាង្គ និងអ្វីៗចេញពីទ្វីបគឺជាប្រភពដើមនៃការមកដល់នៃវត្ថុធាតុជីវពន្ធទឹកសមុទ្រ។ កត្តាជាបន្តបន្ទាប់ជះឥទ្ធិពលលើរបាយនៃវត្ថុធាតុជីវពន្ធៈ ឌីណាមីកនៃទឹក និងរស្មីសំយោគនៅផ្ទៃលើទឹកដោយភ្លៀង។

**-នៅខែកុម្ភៈ** ចំណុះស៊ីលីស្យូមនៅស្រទាប់លើមានពី៣០មីលីក្រាម-ម៉ាស់អាតូម/លីត្រនៅភាគខាងលិច ទៅ ១០-២០មីលីក្រាម-ម៉ាស់អាតូម/លីត្រ នៅកន្លែងផ្សេងទៀតនៃសមុទ្រកម្ពុជា។ នៅជិតស្រទាប់បាតការប្រែប្រួលនៃចំណុះស៊ីលីស្យូមក៏មិនជាសំខាន់ដែរ(២០-៣៥មីលីក្រាម-ម៉ាស់អាតូម/លីត្រ)។ របាយហ្វូសហ្វាតនៅស្រទាប់លើទឹកមានលក្ខណៈប្រមូលផ្តុំដាច់ដោយឡែកពីគ្នា ដោយចំណុះវាប្រែប្រួលពីសូន្យទៅដល់ ០,៣មីលីក្រាម-ម៉ាស់អាតូម/លីត្រ។ ចំណុះអប្បបរិមានៃហ្វូសហ្វាត ត្រូវកត់ត្រាបាននៅភាគខាងជើង និងនារតីនៃតំបន់។ ការផ្លាស់ប្តូរចំណុះជាហ្វូសហ្វាតស្ថិតនៅដូចគ្នាពីផ្ទៃលើដល់បាត។

**-នៅខែមេសា** នៅស្រទាប់លើចំណុះស៊ីលីស្យូមមានពី១០-២០មីលីក្រាម-ម៉ាស់អាតូម/លីត្រ ហើយនៅ ជិតស្រទាប់បាត មានពី២០ ទៅដល់៣៥មីលីក្រាម-ម៉ាស់អាតូម/លីត្រ។ ការប្រមូលផ្តុំជាអតិបរិមានៅស្រទាប់ជាប់បាតសមុទ្រ ត្រូវបានសង្កេតឃើញនៅភាគខាងលិច ឯការប្រមូលផ្តុំជាអប្បបរិមាគឺនៅភាគខាងកើត។ចំណុះហ្វូសហ្វាតប៉ាន់ស្មាននៅខែនេះនៅស្រទាប់លើទឹក មានការប្រែប្រួលពី ០,១ ទៅ ០,៤មីលីក្រាម-ម៉ាស់អាតូម/លីត្រ។ នៅស្រទាប់ជាប់បាតសមុទ្រ ការប្រែប្រួលជាពិសេសគឺ ពី០,៥ ទៅ ១,០មីលីក្រាម-ម៉ាស់អាតូម/លីត្រ លើកលែងតែការប្រមូលផ្តុំជាអតិបរិមារបស់ពួកវានៅភាគខាងជើង និងត្បូង នៃតំបន់ប៉ុណ្ណោះ។

**-នៅខែឧសភា** ចំណុះខ្ពស់បំផុតនៃស៊ីលីស្យូម ត្រូវរកឃើញនៅក្នុងទឹកតំបន់ជិតឆ្នេរ ចាប់ពីផ្ទៃលើទៅដល់បាត ដែលក្នុងពេលនេះចំណុះអតិបរិមាដាច់ខាតនៃសារធាតុស៊ីលីស្យូម (១០មីលីក្រាម-ម៉ាស់អាតូម/លីត្រ) ត្រូវកត់ត្រាបាននៅជាប់ស្រទាប់បាតជំរៅ៨០មែត្រ។ នៅភាគខាងត្បូងបំផុតនៃតំបន់ចំណុះស៊ីលីស្យូម បានប្រែប្រួលពីសូន្យទៅ១៤មីលីក្រាម-ម៉ាស់អាតូម/លីត្រ។នៅស្រទាប់បាតការប្រមូលផ្តុំសារធាតុស៊ីលីស្យូម ប្រែប្រួលក្នុងកំរិតពី២ ទៅ ១០មីលីក្រាម-ម៉ាស់អាតូម/លីត្រ។ ការប្រមូលផ្តុំនៃសារធាតុហ្វូសហ្វាតនៅគ្រប់ស្រទាប់ទឹក នៃតំបន់សិក្សាបានផ្លាស់ប្តូរពីសូន្យទៅ២០មីលីក្រាម-ម៉ាស់អាតូម/លីត្រ។ការប្រមូលផ្តុំនៃសារធាតុហ្វូសហ្វាតនៅតំបន់ជាប់ឆ្នេរនិងនៅភាគខាងជើងនៃតំបន់មានភាពខ្សោយជាងកន្លែងដទៃទៀត នៃដែនទឹកសមុទ្រកម្ពុជា។

**-នៅខែមិថុនា** ចំណុះសារធាតុស៊ីលីស្យូមក្នុងម៉ាស់ទឹកមិនមានអ្វីជាសំខាន់ទេ (១-១៧ មីលីក្រាម-ម៉ាស់អាតូម/លីត្រ)។ចំណុះខ្សោយបំផុតនៃសារធាតុស៊ីលីស្យូម ត្រូវគេបានកត់ត្រានៅភាគកណ្តាល និងភាគខាងលិចនៃតំបន់ (<១មីលីក្រាម-ម៉ាស់អាតូម/លីត្រ)។ ចំណុះសារធាតុហ្វូសហ្វាត នៅស្រទាប់លើក្នុងខែមិថុនា ប្រែប្រួលពី ០,១ ទៅ ០,៤មីលីក្រាម-ម៉ាស់អាតូម/លីត្រ ក្នុងភាគដ៏ធំនៃតំបន់ស្រាវជ្រាវ រហូតដល់ ២,២មីលីក្រាម-ម៉ាស់អាតូម/លីត្រ នៅជិតខ្សែបន្ទាត់ឆ្នេរ។ ការកើនឡើង នៃចំណុះសារធាតុហ្វូសហ្វាតនៅជិតច្រាំងគឺដោយសារលំហូរទឹកសាបពីដីគោក។ នៅខែមិថុនា ចំណុះសារធាតុហ្វូសហ្វាតនៅគ្រប់ស្រទាប់ទឹកនៃតំបន់សមុទ្រកម្ពុជាគឺតិចជាងពី ០,៣ ទៅ ០,៥មីលីក្រាម-ម៉ាស់អាតូម/លីត្រ។

**-នៅខែកក្កដា** របាយសារធាតុស៊ីលីស្យូមនិងហ្វូសហ្វាត ដូចគ្នានឹងខែមុនៗដែរ មានលក្ខណៈបែកជាបណ្តុំតូចៗ។ នៅស្រទាប់លើទឹកអត្រាសារធាតុស៊ីលីស្យូមប្រែប្រួលពីសូន្យនៅភាគខាងត្បូងនៃតំបន់រហូតដល់ ១៨-២៤មីលីក្រាម-ម៉ាស់អាតូម/លីត្រ នៅជិតច្រាំងនៃតំបន់ខាងជើង។ នៅជិតស្រទាប់បាត ចំណុះសារធាតុស៊ីលីស្យូម ប្រែប្រួលពី១០ ទៅ ២៦ មីលីក្រាម-ម៉ាស់អាតូម/លីត្រ។ចំណុះសារធាតុហ្វូសហ្វាតនៅគ្រប់ស្រទាប់ស្ទើរតែដូចគ្នាទាំងអស់នៅក្នុងខែកក្កដា គឺមិនមានអ្វីជាសំខាន់ទេ (ពី០ ទៅ ០,០៨ មីលីក្រាម-ម៉ាស់អាតូម/លីត្រ)។ នៅស្រទាប់លើនៃភាគដ៏ធំនៃតំបន់សមុទ្រកម្ពុជាគឺមានប្រហែលសូន្យ។ នៅជិតស្រទាប់បាត ចំណុះសារធាតុហ្វូសហ្វាត កើនឡើងតិចតួច ក៏ប៉ុន្តែការប្រមូលផ្តុំរបស់វា ក៏មិនជាសំខាន់ដែរ (០,០៦-០,១៨ មីលីក្រាម-ម៉ាស់អាតូម/លីត្រ)។

### ៥.២.៥ អុកស៊ីហ្សែនដែលរលាយ (dissolved oxygen)

លក្ខណៈ នៃរបាយអុកស៊ីហ្សែនក្នុងបរិស្ថានសមុទ្រ ជាសន្ទស្សន៍ នៃការបង្កើតម៉ាស់ទឹក និងអតិក្រមគីមីសាស្ត្រ និងរូបសាស្ត្របានកើតមានឡើង។ ដំណើរឆ្លងកាត់ នៃសារធាតុអុកស៊ីហ្សែនពីស្រទាប់អាកាសទៅក្នុងទឹកសមុទ្រ បានបង្កើតនៅក្នុងលក្ខខណ្ឌដែលនៅអាចទទួលបាន។នៅពេលសីតុណ្ហភាពនិងកំហាប់អំបិលទឹកសមុទ្រទាប ការរលាយអុកស៊ីហ្សែនកាន់តែសកម្ម។ នៅពេលដែលទឹកកាន់តែថ្លា អុកស៊ីហ្សែនកាន់តែជួយដល់ផលិតកម្មហ្វីតូប្លង់តុង។ ជំរៅទឹកដែលបរិមាណអុកស៊ីហ្សែនផលិតដោយហ្វីតូប្លង់តុងស្មើនឹងបរិមាណសរុបនៃអុកស៊ីហ្សែន (១០០ %) ត្រូវបានឲ្យឈ្មោះថា ការទូទាត់គ្នាយ៉ាងច្បាស់លាស់ (precise compensation)។ ឈូងសមុទ្រថៃដែលមានសមុទ្រ កម្ពុជានៅក្នុងនោះដែរ ត្រូវបានគេឲ្យដឹងថាជាតំបន់ដែលមានប្រពលភាពស្មើសំយោគខ្ពស់បំផុត។

**-នៅខែកុម្ភៈ** មួយភាគធំនៃសមុទ្រកម្ពុជា គេសង្កេតឃើញថា មានតិត្ថិភាពលើសលប់នៃអុកស៊ីហ្សែន (oxygen supersaturation) នៅផ្ទៃលើទឹកពី១០២-១០៣%។ ចំណុះអុកស៊ីហ្សែននៅស្រទាប់លើទឹក ប្រែប្រួលពី៤,២ ទៅ ៤,៨មល/ល។ នៅតំបន់ឆកកោះកុង តិត្ថិភាពលើសលប់មានដល់១០៥%។ ទឹកសមុទ្រនៅកន្លែងរាក់ដែលរួមមានឆកកំពង់សោមមានតិត្ថិភាពនៅស្រទាប់លើទឹកពី ៩៨-៩៩% (៤,៥-៤,៦មល/ល) និងនៅភាគខាងត្បូងឆៀងលិចនៃតំបន់ដែលស្រទាប់លើទឹកមានតិត្ថិភាពដល់ ៩១% (៤,២-៤,៦មល/ល) ដែលភ្ជាប់តំបន់ទៅនឹងចំណុះទាបនៃអុកស៊ីហ្សែន។ ដូច្នេះបើការធ្លាក់ចុះនៃចំណុះអុកស៊ីហ្សែននៅតាមបណ្តោយច្រាំង ប្រហែលជាអាចមកពីការជ្រួតជ្រៀតនៃជីវគីមីសាស្ត្រដ៏ខ្លាំងក្លាការចែកចាយអុកស៊ីហ្សែននៅភាគខាងជើងឈៀងលិចនៃតំបន់បានបង្កើតជាតំបូងនៅក្រោមឥទ្ធិពលនៃកត្តាឌីណាមិក។ នៅភាគកណ្តាលនៃតំបន់មានកន្លែងមួយមានចំណុះអុកស៊ីហ្សែនលើសពី៤,៦មល/ល (តិត្ថិភាពតិចជាង ១០០%) ការមានតំបន់បែបនេះបានបញ្ជាក់ផងដែរនូវឌីណាមីកដោយឡែកនៃទឹកទាំងនោះ។ចំណុះអុកស៊ីហ្សែនដែលស្ទើរតែមិនប្រែប្រួលនៅត្រឹមកំរិតជំរៅ២០

ម៉ែត្រ។ ជំរៅទឹក២០ម៉ែត្រជាមធ្យម គឺជាចំណុចទូទាត់គ្នា (ចំណុចដែលឧស្ម័នកាបូនិកភាយចេញពីការដកដង្ហើមនៃសរីរាង្គជីវស្មើទៅនឹងអ្វីដែលពួកវាបានស្រូបយកនៅពេលធ្វើរស្មីសំយោគ)សម្រាប់ទឹកនៅក្នុងតំបន់សមុទ្រកម្ពុជា។ នៅភាគអគ្នេយ៍នៃតំបន់ស្រាវជ្រាវ ទឹកនៅកំរិតនេះគឺមានតិត្ថិភាពបន្ទាប់បន្សំបណ្ដាលមកពីការចូលលាយឡំ នៃជីវតិមីសាស្ត្រដ៏ខ្លាំងក្លាដែលបានបញ្ជាក់ដោយមិនចំតាមផលិតភាពជីវសាស្ត្រខ្ពស់នៃទឹកបើប្រៀបធៀបជាមួយភាគធំនៃតំបន់។ នៅកំរិតជំរៅទឹក៥០ម៉ែត្រ ប្រពល ភាពនៃសំយោគមានកំរិតទាបដែលដូច្នេះហើយទើបទឹកមិនមានតិត្ថិភាព (saturation) អុកស៊ីហ្សែនដូចគ្នាជាទូទៅទេ។ ភាគច្រើននៅភាគ ខាងលិចនៃតំបន់នៅកំរិតជំរៅ៥០ម៉ែត្រ តិត្ថិភាពបានធ្លាក់ចុះដល់៥០% (២,៣មល/ល) ដែលបញ្ជាក់តាមការកើនឡើងនៃទឹក និងតាមការចូលលាយឡំនៃជីវតិមីសាស្ត្រដ៏ខ្លាំងក្លា។ នៅស្រទាប់បាត ការចែកចាយអុកស៊ីហ្សែនក៏កើតឡើងដោយសារសណ្ឋានដីផងដែរ។នៅទីទឹកជ្រៅភាគច្រើនតិត្ថិភាពមានមិនលើស ពី៥០-៦០%ហើយនៅតំបន់ឆ្នេរទឹករាក់នៃឆកកោះកុងនិងនៅមាត់ច្រកឆកកំពង់សោមវាមានទៅដល់១០១-១០៣% (៤,៥-៤,៦មល/ល) ដែលទាំង នេះបានបង្ហាញតាមកំដៅយ៉ាងខ្លាំងនៃទឹកនិងជាលទ្ធផលដោយរស្មីសំយោគដ៏ខ្លាំងក្លា។នៅខាងត្បូងកោះរ៉ៃប្រហែលអាចដល់ទៅ៤,៥ម៉ែល៍គេបានកត់ត្រានូវតិត្ថិភាពមួយនៃទឹកដែលមានអុកស៊ីហ្សែនស្មើ ។

**-នៅខែមេសា** ការបង្កើនការចាំងចូលកាំរស្មីព្រះអាទិត្យ ជំរុញឲ្យមានការកើនឡើងបរិមាណអុកស៊ីហ្សែនដែលផលិតដោយការធ្វើរស្មីសំយោគជាបន្តបន្ទាប់បើប្រៀបទៅនឹងខែកុម្ភៈ។ នៅពេលនេះជាមួយនឹងអ្វីទាំងនេះការរលាយរបស់វាបានថយចុះតិចតួចដោយសារការកើនសីតុណ្ហភាព និងកំហាប់អំបិល នៃទឹកដែលធ្វើអង្កេតនៅក្នុងសមុទ្រកម្ពុជា។ ដូច្នេះបរិមាណអុកស៊ីហ្សែនដែលរលាយនៅស្ទើរ តែមិនប្រែប្រួលទេ បើប្រៀបទៅនឹងរដូវរំហើយ។ តម្លៃអតិបរិមានៃអុកស៊ីហ្សែនដែលរលាយ(៥មល/ល)ត្រូវបានកត់ត្រានៅផ្នែកទឹករាក់ ជិតព្រំដែនខាងជើងនៃតំបន់។ តម្លៃអតិបរិមា (៤,៤មល/ល) ត្រូវបានវាស់វែងនៅច្រកចូលឆកកំពង់សោម។ ចំណុចទូទាត់ឋិតនៅចន្លោះទីជំរៅទឹក២០-៣០មែត្រ។ ចំណុះអុកស៊ី-ហ្សែននៅស្រទាប់បាតប្រែប្រួលពី ២-២,៥មល/លនៅភាគខាងត្បូងនៃតំបន់ រហូតដល់៤,០មល/លនៅក្នុងទឹក ជិតឆ្នេរ។

**-នៅខែឧសភា** អត្រាអុកស៊ីហ្សែននៅស្រទាប់លើទឹកប្រែប្រួលពី៤,២ទៅ៤,៩មល/ល។ ចំណុចទូទាត់ឋិតនៅកំរិត២០ម៉ែត្រ។ បន្ទាប់មកគេឃើញមានការថយចុះភាពខាប់នៃអុកស៊ីហ្សែនយ៉ាងលឿនទៅតាមខ្នាត ដែលជំរៅកាន់តែកើនឡើង។ ចំណុះអុកស៊ីហ្សែនប្រែប្រួលពី៤,៤ទៅ៤,៦មល/លនៅកំរិត២០ម៉ែត្រ រហូតដល់២,២មល/ល នៅជិតបាតសមុទ្រ។ តម្លៃអតិបរិមានៃភាពខាប់របស់អុកស៊ីហ្សែន (៤,២មល/ល) នៅជិតបាតសមុទ្រត្រូវបានរកឃើញនៅព្រំដែនខាងត្បូងនៃតំបន់ស្រាវជ្រាវដែលនៅព្រំដែលខាងលិច (៤,២-៤,៤មល/ល) ជាកន្លែងដែលបង្ហាញការធ្លាក់ចុះនៃទឹក។

**-នៅខែមិថុនា** ចំណុះអុកស៊ីហ្សែននៅស្រទាប់ទឹកជំរៅ០-២០មែត្រ មានជាមធ្យម៤,៤មល/ល។ ចំណុចទូទាត់ គឺនៅជំរៅទឹកពី ២០-៣០ម៉ែត្រ មួយភាគធំ និងនៅជំរៅទឹក១០-២០ម៉ែត្រក្បែរច្រាំង។ នៅជិតបាតសមុទ្រ ចំណុះអុកស៊ីហ្សែនប្រែប្រួលពី៣,០-៤,៥មល/ល។

**-នៅខែកក្កដា** នៅស្រទាប់លើទឹក ការប្រមូលផ្ដុំអុកស៊ីហ្សែនមានពី ៤,៤ ទៅ ៤,៨មល/ល។ ដោយមិនរាប់បញ្ចូលតំបន់ឆ្នេរទេនោះភាគច្រើននៃដែនទឹកកំណត់នៃតំបន់សមុទ្រកម្ពុជា មានផ្ទុកអុកស៊ីហ្សែននៅស្រទាប់លើនៅទីតាំងចាប់ពីជំរៅ០ទៅ៣០ម៉ែត្រនៅក្នុងកំរិត ៤,៥-៤,៦មល/ល (តិត្ថិភាព១០១-១០៣%)។ ចំណុះអតិបរិមានៃអុកស៊ីហ្សែនត្រូវបាន

កត់ត្រានៅតំបន់ដែលមាន ការមកដល់នៃទឹកមកពីឆកកោះកុង។ កំរិតជំរៅទឹក៣០មែត្រ ប្រាប់ឲ្យគេដឹងថា តំបន់មួយដែលមានចំណុះអុកស៊ីហ្សែនខ្ពស់បិតនៅភាគនិរតីនៃកោះព្រីងដែលបង្ហាញនូវការធ្លាក់ចុះនៃទឹកនៅតំបន់នេះ។ ក្បែរបាតសមុទ្រ ការប្រមូលផ្តុំជាអប្បបរិមានៃអុកស៊ីហ្សែនអាចដល់២,៣-៣មល/ល (៥០-៧០%) នៅព្រំដែនខាងជើងនៃតំបន់។ តំបន់នៃចំណុះអុកស៊ីហ្សែនទាបមានរាងទ្រវែងនៅភាគខាងត្បូង ទៅតាមខ្សែបន្ទាត់ជំរៅទឹក៥០ម៉ែត្រ និង៦០មែត្រ។ការបង្កើតតំបន់នេះគឺដោយសារចរន្តខាងត្បូងនៅស្រទាប់បាតដែលបង្កើតជាភ្នែនព្យុះស៊ីក្លូន។ តំបន់ដែលបង្ហាញលក្ខណៈតាមចំណុះអុកស៊ីហ្សែនទាបត្រូវបានសង្កេតឃើញរហូតដល់ព្រំដែនខាងត្បូងនៃតំបន់។ ចូលកាន់តែជិតទៅដល់ច្រាំង ចំណុះអុក-ស៊ីហ្សែនកើនឡើងពី ៣,៨-៤,៤មល/ល (តិត្ថិភាព ៨៤-៩៩%) នៅជិតស្រទាប់បាត។ ការបង្កើតស្នាមនៃការប្រមូលផ្តុំអុកស៊ីហ្សែនទាបអាចបង្កឡើងតាមការប្រើប្រាស់សម្រាប់អុកស៊ីតកម្មនៃសារធាតុសរីរាង្គដែលធ្វើបានយ៉ាងរហ័សនៅផ្ទៃលើទឹក។ចំណុចនៃការយកមកទូទាត់គ្នា (compensation) គឺនៅក្នុងខែកក្កដានៅកំរិតជំរៅទឹក៣០-៦០ម៉ែត្រនិងក្នុងតំបន់ជិតឆ្នេរនៅកំរិតជំរៅទឹកពី៥-១០ម៉ែត្រ។

### ៥.២.៦ ពណ៌ និងតម្លាភាពនៃទឹក

នៅក្នុងខែកក្កដាឆ្នាំ១៩៨៣ ការវាស់ស្ទង់តម្លាភាពនៃទឹកនៅសមុទ្រកម្ពុជាត្រូវបានធ្វើប្រកបដោយប្រសិទ្ធភាព ដោយប្រើថាស Secchi និងតាមរបៀបដែលអាចមើលឃើញពេលទម្លាក់ឧបករណ៍នេះចុះទៅក្រោមសមុទ្រ។ នៅតាមស្ថានីយ៍ក្បែរឆ្នេរទឹកមានពណ៌បៃតង៩-១០ (ទៅតាមខ្នាតនៃភាពភ្លឺ) និងភាពថ្លាឆ្វេង-៧-១០ម៉ែត្រ។ការអង្កេតដែលធ្វើទៅលើឧបករណ៍ទម្លាក់ចុះទៅក្រោមសមុទ្រ បានបង្ហាញពីការថយចុះ ភាពថ្លាឆ្វេងភ្លាមៗ នៅជំរៅ ១-២ម៉ែត្រ។ នៅភាគកណ្តាលនៃតំបន់សមុទ្រកម្ពុជា ទឹកមានពណ៌ខៀវនិងបៃតងខៀវ (៤-៤) និងភាពថ្លាឆ្វេងមានពី១៥-២០ម៉ែត្រ។នៅភាគខាងលិចភាពថ្លាឆ្វេងមានទៅដល់ជំរៅ២៦ម៉ែត្រ។នៅស្រទាប់បាតភាពថ្លាឆ្វេងមានមិនលើសពី៣-៥ម៉ែត្រឡើយដែលជាលទ្ធផលនៃការបែកខ្ញែកសារធាតុអណ្តែត ទៅតាមលក្ខខណ្ឌតិត្ថិភាព (saturation) ដែលភាពថ្លាឆ្វេងមិនមានលើសពី ៣-៥ម៉ែត្រឡើយ។

### ៥.២.៧ សេចក្តីសន្និដ្ឋាន

ទោះជាលក្ខណៈឧតុនិយម និងសាគរសាស្ត្រទាំងឡាយនៅក្នុងតំបន់សមុទ្រកម្ពុជាមិនបានបង្ហាញជាទូទៅ ពីចលនាទៅមកគួរឲ្យកត់សំគាល់ឡើយ។ ការវិភាគនៅក្នុងតារាងលេខ៣ខាងក្រោម បង្ហាញថាសីតុណ្ហភាពនៅស្រទាប់ទឹកខាងលើនៃតំបន់សមុទ្រកម្ពុជាមានមិនទាបជាង២៧អង្សាសេឡើយនៅទូទាំងឆ្នាំ។ នៅពេលជាមួយគ្នានេះដែរ សីតុណ្ហភាពនៃអាកាសធាតុអាចធ្លាក់ចុះពី ២៤ ទៅ ២៣,៥០អង្សា-សេ។ ដែនកំហាប់អំបិលបានកត់ត្រានូវការប្រែប្រួលយ៉ាងធំធេញ ឬនៅអំឡុងរដូវវស្សា កំហាប់អំបិលនៅស្រទាប់លើ នៅតាមតំបន់ឆ្នេរនៃដែនទឹកអាច ថយរហូតដល់ ២៧,៤‰ តាមលក្ខខណ្ឌរក្សាតម្លៃខ្ពស់នៃកំហាប់អំបិលរហូតដល់៣២,៦-៣៣‰នៅព្រំដែនខាងត្បូង នៃតំបន់សមុទ្រកម្ពុជាដោយសារការចូលមកដល់នៃទឹកប្រៃខ្លាំងពីសមុទ្រចិនខាងត្បូង។ចំណុះវត្ថុធាតុជីវពន្ធ នៅស្រទាប់លើទឹកនៃតំបន់ស្រាវជ្រាវបង្ហាញចលនាឡើងចុះក្នុងមួយឆ្នាំៗដូចតទៅ៖ នៅពេលសារធាតុហ្វូសហ្វាតមាន ២,២ មីលីក្រាម-ម៉ាស់អាតូម/លីត្រ និងសារធាតុស៊ីលីកេត (silicate) មាន ៣០មីលីក្រាម-ម៉ាស់អាតូម/លីត្រនោះ ត្រូវតែបន្ថែមនៅខាងចុងថា ចំណុះអប្បបរិមានៃវត្ថុធាតុជីវពន្ធគឺស្មើនឹងសូន្យតាមការវិភាគ។ ចំណុះអុកស៊ីហ្សែននៅស្រទាប់លើទឹក ស្ទើរតែមិនប្រែប្រួលទូទាំងឆ្នាំ។ អប្ប-បរិមាដាច់ខាត នៃការប្រមូលផ្តុំរបស់សារធាតុនេះសមាសធាតុនេះ គឺនៅខែមិថុនា ដោយសារជីវគីមីសាស្ត្រចូលមកលាយឡំជាមួយនៃអុកស៊ីហ្សែនយ៉ាងសកម្មជាធម្មជាតិ (តារាង៣)។

### តារាង៣. គុណតម្លៃខ្ពស់បំផុតនៃលក្ខណៈរូប-គីមីសាស្ត្រ ( physio-chemistry ) ដែលកត់ត្រាបាននៅស្រទាប់លើទឹកនៃតំបន់សមុទ្រកម្ពុជា និងសីតុណ្ហភាពអាកាសធាតុនៅពីលើសមុទ្រ

| សន្ទស្សន៍ | សីតុណ្ហភាពទឹក (អង្សាសេ) | | កំហាប់អំបិល (ភាគពាន់ ‰) | | ស៊ីលិកេត (មក្រ-ម៉ាស់អាតូម/លីត្រ) | | ហ្វូសហ្វេត (មក្រ-ម៉ាស់អាតូម/លីត្រ) | | អុកស៊ីហ្សែន (មីលីលីត្រ/លីត្រ) | | សីតុណ្ហភាពអាកាសធាតុ (អង្សាសេ) | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ពេលអង្កេត | អតិបរិមា | អប្បបរិមា | អតិបរិមា | អប្បបរិមា | អតិបរិមា | អប្បបរិមា | អតិបរិមា | អប្បបរិមា | អតិបរិមា | អប្បបរិមា | អតិបរិមា | អប្បបរិមា |
| ធ្នូ | ២៧,០ | ៣០,៥ | ២៩,៥ | ៣០,៥ | - | - | - | - | - | - | ២៤,០ | ៣២,០ |
| កុម្ភៈ | ២៧,១ | ២៩,៤ | ៣០,៧ | ៣២,៤ | ១០. | ៣០. | ០. | ០,៣ | ៤,២ | ៤,៨ | ២៥,០ | ៣៤,៦ |
| មេសា | ២៩,៨ | ៣០,១ | ៣១,៨ | ៣៣,៨ | ១០. | ២០. | ០. | ០,៤ | ៤,៥ | ៤,៩ | ២៧,១ | ៣៧,៣ |
| ឧសភា | ៣០,០ | ៣០,៩ | ៣១,៣ | ៣៣,០ | ៦. | ៩. | ០. | ២,០ | ៤,៨ | ៤,៩ | ២៥,១ | ៣១,២ |
| មិថុនា | ២៨,៥ | ២៩,០ | ៣១,៥ | ៣៣,៥ | ០. | ១០. | ០,១ | ២,២ | ៤,៣ | ៤,៧ | ២៥,៤ | ៣២,៨ |
| កក្កដា | ២៨,៥ | ២៩,៧ | ២៧,៤ | ៣២,៦ | ០. | ២៤. | ០,១ | ៣,៨ | ៤,៨ | ៤,៨ | ២៣,៥ | ៣៣,០ |
| កញ្ញា-តុលា | ២៨,០ | ២៩,៥ | ២៩,០ | ៣២,០ | - | - | - | - | - | - | ២៤,៥ | ៣២,៥ |
| តុលា-វិច្ឆិកា | - | - | - | - | - | - | - | - | - | - | ២៦,០ | ៣៣,៥ |

## ៥.៣ ធនធានជលផល

### ៥.៣.១ បច្ចេកទេសក្នុងការប៉ាន់ស្មានស្តុកត្រី

ការធ្វើនេសាទដោយប្រើឧបករណ៍នេសាទអួនអូសដល់បាតសមុទ្រ៣ប្រភេទ ដែលមានប្រវែងបណ្តោយនិងទំហំវិជ្ជមាត្រនៃមាត់បើកខុសៗគ្នាដើម្បីធ្វើតេស្តផលិតភាពរបស់ឧបករណ៍និមួយៗដោយត្រូវធ្វើប្រតិបត្តការនេសាទ នៅតាមស្ថានីយស្រាវជ្រាវសាគរសាស្ត្រទាំងអស់ និងស្ថានីយស្រាវជ្រាវជីវ-សាស្ត្រដែលបង្កើតថ្មីមួយចំនួនទៀត។ តេស្តឧប-ករណ៍អួនអូសតាមប្រតិបត្តិការនេសាទរយៈពេលមួយម៉ោងនៅតាមស្ថានីយ៍មួយចំនួនបានបង្ហាញថាប្រភេទអួនអូសស្រទាប់បាតប្រវែង៤៣ម៉ែត្រមានប្រសិទ្ធភាពខ្ពស់ជាងគេ។

នៅអំឡុងឆ្នាំ១៩៨៣-១៩៨៦ ប្រតិបត្តិការនេសាទដោយអួនអូសត្រូវបានធ្វើចំនួន៧លើកដែលផ្ទៃក្រឡានៃផ្ទៃទឹកដែលបានធ្វើនេសាទមួយលើកៗមានទំហំមិនដូចគ្នាទេ។ នៅឆ្នាំ១៩៨៣ នាវា Herackles អនុវត្តនៅលើផ្ទៃក្រឡាចំនួន ៨.៤០៥ម២ ដែលតំបន់ដែលនៅជាប់នឹងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ប្រទេសថៃមិនត្រូវបានរុករកឡើយនៅដំណាក់កាលនេះ។ ជាងនេះទៅទៀត ផ្ទៃសមុទ្រចំនួន ២.០០០ម$^{២}$ នៅភាគពាយ័ព្យនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់កម្ពុជាក៏មិនបានធ្វើការរុករកដែរ ព្រោះតែស្ថានភាពបាតសមុទ្រមិនអំណោយដល់ការអនុវត្តការនេសាទដោយអួន អូសដោយបាតសមុទ្រតំបន់នេះ មានថ្មរឆេញរឆុញមិនរាបស្មើអាចបង្ករការខូចខាតដល់ឧបករណ៍នេសាទអួនអូស។ ដូច្នេះការស្រាវជ្រាវវិទ្យាសាស្ត្រដំណាក់កាលនេះបានបង្ហាញថា ស្តុកត្រីមានតែ ១៧.៦០០តោនប៉ុណ្ណោះ (តារាង៤)។

នៅក្នុងដំណាក់កាលស្រាវជ្រាវ នាអំឡុងខែឧសភា ឆ្នាំ១៩៨៥ នាវា Chantar បានធ្វើការរុករកនៅលើផ្ទៃសមុទ្រចំនួន ១២.៦២០ម$^{២}$។ នៅភាគពាយ័ព្យនៃសមុទ្រកម្ពុជាដែលស្ថានភាពបាតសមុទ្រមិនអំណោយដល់ការធ្វើនេសាទអួនអូសប្រតិបត្តិការនេះត្រូវបានអនុវត្តតែពីរលើកប៉ុណ្ណោះក្នុងដំណាក់កាលនេះដើម្បីអាចមានមូលដ្ឋានធ្វើការប៉ាន់ស្មានសមាសភាពដោយឡែកនិងផលស្តុកធនធានត្រីដែលត្រូវប៉ាន់ស្មានដោយផ្អែកលើការបកស្រាយចេញពីផ្ទៃសមុទ្រដែលបានសិក្សា។ ស្តុកត្រីសេដ្ឋកិច្ចមាន ៤៦.២១២ តោនដែលក្នុងនោះដង់ស៊ីតេមធ្យមក្នុងតំបន់ទាំងមូលដែលប៉ាន់ស្មានមាន ៣,៦៦តោន/ម$^{២}$។ នៅខែមិថុនា-កក្កដា ឆ្នាំ១៩៨៥ ការវាយតម្លៃស្តុកទៅតាមផ្ទៃសមុទ្រ ដែលបានសិក្សាចំនួន១០.៤២៥ម$^{២}$ ជាមួយការប្រមាណទុកទៅតាមទិន្នន័យដែលបានសិក្សាកាលពីខែឧសភាកន្លងមក សម្រាប់តំបន់នៅភាគពាយ័ព្យដែលមានបាតសមុទ្រប្រកបដោយគ្រោះថ្នាក់បានបង្ហាញថាមានចំនួន ៥៦.៨០០តោន ដែលក្នុងនោះដង់ស៊ីតេមធ្យមអាចឡើងដល់ ៥,៤៥តោន/ម$^{២}$ (តារាង៤ )។

នៅអំឡុងមករា-កុម្ភៈ និងមិនា-មេសា ឆ្នាំ១៩៨៦ នាវា Chantar បានធ្វើប្រតិបត្តិការរុករកចំនួនពីរលើក ដោយគ្របដណ្តប់លើផ្ទៃសមុទ្រចំនួន ១១.២០០ម² នៅលើកទី១ និង ១១.៩០០ម² នៅលើកទី២។ ស្តុកត្រីត្រូវបាន ប៉ាន់ស្មានថាមានចំនួន ៥៩.៣៤២តោន នៅខែមករា-កុម្ភៈ និងចំនួន ៥៨.៥៤០តោននៅខែមិនា-មេសា (តារាង៤)។

តារាង៤.ស្តុកត្រីសេដ្ឋកិច្ចនៅក្នុងសមុទ្រកម្ពុជាដែលប៉ាន់ស្មានចេញពីផលដែលនេសាទបានពីប្រតិបត្តិការ អួនអូសដោយនាវាស្រាវជ្រាវចាប់ពីឆ្នាំ១៩៨៣ដល់១៩៨៦

| ឈ្មោះនាវា | ដំណាក់កាលធ្វើការងារ | ផ្ទៃក្រឡាដែលសិក្សា (ម²) | ដង់ស៊ីតេមធ្យម នៃ ជីវម៉ាស់ (តោន/ម²) | ស្តុកសេដ្ឋកិច្ច (□= 0,៥ ) |
|---|---|---|---|---|
| Herackles | កក្កដា ១៩៨៣ | ៨.៤០៥ | ១,១០១ | ១៧.៦៨៥ |
| Chantar | ឧសភា ១៩៨៥ | ១២.៦២០ | ៣,៦៦៤ | ៤៦.៨១៨ |
| Chantar | មិថុនា-កក្កដា ១៩៨៥ | ១០.៤២៥ | ៥,៤៥ | ៥៦.៨២២ |
| Ouglekamensk | កញ្ញា-តុលា១៩៨៥ | ៦.៨៨៨ | ៥,៥៦ | ៣៨.២៤៨ |
| Ouglekamesk | ធ្នូ ១៩៨៥ | ៥.៨៩០ | ៤,៧៥ | ២៩.០១០ |
| Chantar | កុម្ភៈ ១៩៨៦ | ១១.២៥៥ | ៥,២៧២ | ៥៩.៣៤២ |
| Chantar | មេសា ១៩៨៦ | ១១.៩២៣ | ៤,៩០៩ | ៥៨.៥៤០ |

ដើម្បីប៉ាន់ស្មានផលស្តុក និងផលបម្រុងនៃធនធានត្រីគេត្រូវប្រើប្រាស់បច្ចេកទេសផ្ទៃក្រឡាដែលក្នុងនោះ ផលត្រីចាប់បានដោយប្រតិបត្តិការអួនអូសទាំងអស់ ត្រូវបូកសរុបចូលគ្នា ហើយចែកនឹងចំនួនប្រតិបត្តិការនេសាទ ដើម្បីរកមធ្យមភាគ។ ផ្ទៃក្រឡានេសាទនិមួយៗ ត្រូវគណនាតាមផ្ទៃក្រឡាមាត់បើកនៃអួនអូស និងល្បឿនអូសក្នុងរយៈពេលមួយម៉ោង (តារាង៤)។ ដូច្នេះការប៉ាន់ស្មានស្តុកត្រូវធ្វើទៅតាមសមីការដូចខាងក្រោម៖

M =(S . m)/(S1 .q )

M: ស្តុកត្រី គិតជាតោន

S:ផ្ទៃក្រឡាតំបន់សិក្សា (គិតជាម២)

S1:ផ្ទៃក្រឡាដែលអូសអួនរយៈពេលមួយម៉ោង

m:ផលត្រីដែលចាប់បានដោយប្រតិបត្តិការអូសអួនរយៈពេលមួយម៉ោងគិតជាតោន

q:មេគុណនៃសមត្ថភាពនេសាទស្មើនឹង0,៥

## ៥.៣.២ ស្តុកសេដ្ឋកិច្ចនៃត្រីនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃសមុទ្រកម្ពុជា

ដោយផ្អែកលើទិន្នន័យ ដែលស្រង់ចេញពីលទ្ធផលនៃការនេសាទដោយការអូសអួនពិសោធន៍ស្រាវជ្រាវ នៅពាសពេញតំបន់សេដ្ឋកិច្ចផ្តាច់មុខកម្ពុជា ដោយបានគិតគូរដល់ការកាត់បន្ថយ ៤០% ពីស្តុកត្រី ដែលចេញពីទិន្នន័យច្បាស់លាស់ទាក់ទងទៅនឹងភាគច្រើននៃហ្វូងពួកត្រីតូចៗផងនោះទិន្នផលត្រីនៅក្នុងតំបន់នេះ ត្រូវបានផ្តល់អនុសាសន៍ថា គួរតែអនុញ្ញាតឲ្យធ្វើនេសាទត្រឹមតែ២០,០០០តោន/ឆ្នាំ ដើម្បីចីរភាព។

*(នៅមានត)*

ដោយ ទូច ស៊ាងតាណា

## ១- ពន្យល់ពាក្យ

**ក្ដី-ក្ដាំ .-** តាមវចនានុក្រម បានសេចក្ដីថា៖ អធិករណ៍ទូទៅ វិវាទធម្មតា ...។ កើតក្ដីក្ដាំនឹងគ្នា។ បរិវាសព្ទ ក្ដាំ អាចគន្លាស់បានជាពាក្យក្ដាំព្រោះប្រកាន់រៀងខ្លួនតាមចំណរី ពោលគឺ ក្ដី ព្រោះប្រកាន់រៀងខ្លួនតាមចំណាំ។

**ក្ដួល-ក្ដៅ .-** តាមវចនានុក្រម បានសេចក្ដីថា៖ អួលខ្យល់ ដោយទោមនស្សចិត្ត ក្ដួលក្ដៅក្នុងចិត្ត។ បរិវាសព្ទ ក្ដៅ អាចគន្លាស់បានជាពាក្យ ក្ដៅដោយចិត្តហួងសួលគឺ ក្ដួល ដោយចិត្តសៅ ឬ ក្ដួលឆៅ = ក្ដៅឆួល ។

**ក្មេង-ក្មាង .-** ជាពាក្យខ្មែរមន បានសេចក្ដីថា៖ ក្មេងៗដោយខ្មែរ យើងតាំងពីបុរាណកាលមក មានជាប់ពូជពង្សលាយគ្នាជាមួយសាសន៍មន បានជាយើងមានទម្លាប់ប្រើ ពាក្យ ក្មេងនិងក្មាង ភ្ជាប់ជាមួយគូ ដើម្បីថា ក្មេង-ក្មេង។ បើយើងធ្វើអត្ថាធិប្បាយឱ្យវែងបន្តិចទៅទៀត យើងឃើញថា ពាក្យ ក្មាង នេះ យើងយកមកប្រើជាបរិវារសព្ទនៃពាក្យ ក្មេង ដើម្បីបង្ហាញថា «ក្មាងអ្នកជិតខាង» ប្រែមកថា «ក្មេងអ្នកជិតខាង» ព្រោះខ្មែរយើងច្រើននិយាយថា៖ ក្មេងក្មាង មកពីណា មកលេងទីនេះ ក៏ច្រើនម៉្លេះ ? រឿងនេះ ក្មេងកូនចៅយើងក្ដី ក្មេងកូនចៅអ្នកស្រុកជិតខាងក្ដី ដែលមករត់លេងជាមួយគ្នានោះ ទាល់តែក្មេងទាំងនោះចេះស្គាល់គ្នាជាមិត្តភក្ដិជាអាទិនៅជិតខាងគ្នាទើបរួមលេងជាមួយគ្នាបាន។ ដូច្នេះហើយ បានជាយើងយកពាក្យ ក្មេងក្មាង មកជំនួសពាក្យ ក្មេងៗទៅវិញ។

**សង្គហធម៌ ន.** : គឺជាធម៌សង្គ្រោះមាន៤យ៉ាង ៖

១. ទាន = ធ្វើអំណោយដល់អ្នកដែលគួរឱ្យ

២. បិយវាចារ = ពោលពាក្យគួរឱ្យចង់ស្ដាប់

៣. អត្ថចរិយា = ប្រព្រឹត្តអំពើជាប្រយោជន៍ចំពោះខ្លួន និងចំពោះអ្នកដទៃ

៤. សមានត្តតា = ដាក់ឬពារឱ្យ ល្មមពេញចិត្តអ្នកដទៃ។

**សង្គហវត្ថុ ន.** : គឺជាអង្គនៃសេក្ដីសង្គ្រោះ មាន៤យ៉ាង៖

១. សស្សមេធ = ឈ្លាសវៃក្នុងមុខរបរស្រូវ

២. បុរិសមេធ = ផ្ដល់រង្វាន់ដល់អ្នកធ្វើការ៦ខែម្ដងៗ

៣. សម្មាបាស = ផ្ដល់ទុនដល់អ្នកក្រីក្រ ដោយមិនយកការប្រាក់ក្នុងរយៈពេល៣ឆ្នាំ

៤. វាជបេយ្យ = ពោលពាក្យជាទីស្រលាញ់។

**កាលទាន ន.** : គឺពេលដាក់ទាន ។ កាលទានមាន៥៖

១. អាគន្តុកទាន = ឱ្យទានដល់អ្នកទើបនឹងមកដល់ថ្មី

២. គមិកទាន = ឱ្យទានដល់អ្នករៀបចេញដំណើរទៅឆ្ងាយ

៣. គិលានទាន = ឱ្យទានដល់អ្នកជំងឺ

៤. ទុព្ភិក្ខទាន = ឱ្យទានដល់អ្នកអត់ឃ្លាន

៥. នវទាន = ឱ្យទានជារបស់ដែលទើបនឹងមាន។

## ២- ស្វែងយល់ពី កវីនិពន្ធ កេង វ៉ាន់សាក់

កេង វ៉ាន់សាក់ គឺជាឈ្មោះកវីនិពន្ធខ្មែរមួយរូប ថ្នាក់បណ្ឌិតអក្សរសាស្ត្រ កើតនៅថ្ងៃទី១៩ កញ្ញា ១៩២៥ នៅភូមិកំពង់បឹង ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ បិតានាម កេង ស៊ីផាន់ និងមាតានាម ជៀស ហន ។ មាតារបស់លោក កេង វ៉ាន់សាក់ មុនពេលរៀបការជាមួយឪពុកលោក គឺជាស្រីស្នំម្នាក់នៅក្នុងវាំង។ក្រោយមកម្តាយរបស់លោកបានធ្លាក់ក្នុងអន្លង់ស្នេហ៍របស់ឪពុកលោក។ បន្ទាប់ពីបានប្រឡងជាប់មធ្យមសិក្សាប័ត្រភាគទី២ ផ្នែកទស្សនវិជ្ជា នៅឆ្នាំ១៩៤៦ លោកបានទៅបន្តការសិក្សានៅប្រទេសបារាំង។ ទន្ទឹមគ្នានឹងការសិក្សា លោកបានធ្វើជាសាស្ត្រាចារ្យជំនួយភាសាខ្មែរ នៅសាលាជាតិភាសាបូព៌ាប្រទេស (Ecole Nationale des langues orientales vivantes) នាក្រុងប៉ារីស នៅឆ្នាំសិក្សា ១៩៤៧-៤៨ និង ១៩៥១-៥២)។ នៅចន្លោះពេលនោះលោកបង្រៀនភាសាខ្មែរ នៅសាលាសិក្សាផ្នែកបូព៌ានិងអាហ្វ្រិក នៃសាកលវិទ្យាល័យក្រុងឡុង (School of oriental and african studie London University) ក្នុងឆ្នាំសិក្សា១៩៤៨-១៩៥០។

លោកបានប្រឡងជាប់ បរិញ្ញាប័ត្រអក្សរសាស្ត្រផ្នែកទស្សនវិជ្ជា នៅមហាវិទ្យាល័យ អក្សរសាស្ត្រនិងមនុស្សសាស្ត្រក្រុងប៉ារីសនៅឆ្នាំ១៩៥១។ លោក កេង វ៉ាន់សាក់ មានភរិយាជាជនជាតិបារាំង ឈ្មោះ ស៊ុយសាន កុលលើវីល (Suzane Colleville)។ លោកជាអ្នកដែលបានច្នៃប្រឌិតចេញជាអក្សរខ្មែរ នៅលើម៉ាស៊ីនអង្គុលីលេខ ដែលកាលពីដើមឡើយពិភពលោកនៅមិនទាន់មានម៉ាស៊ីន អ័រឌីណាទ័រអ៊ីបេអិម (Ordinator IBM) ឬហៅថាកុំព្យូទ័រនៅឡើយ។ កាលណោះ មានតែម៉ាស៊ីនអង្គុលីលេខតែប៉ុណ្ណោះរាប់តាំងពីសម័យសង្គ្រាមលោកលើកទី២មក។ ដោយឡែកនៅប្រទេសកម្ពុជាយើង នាសម័យនោះ ក៏មានប្រើម៉ាស៊ីនអង្គុលីលេខនោះដែរ ប៉ុន្តែជាអកុសលម៉ាស៊ីនអង្គុលីលេខកាលណោះមានតែអក្សរឡាតាំង ទើបបានជាលោកកេង វ៉ាន់សាក់ ច្នៃប្រឌិតជាខ្ទង់អក្សរខ្មែរនៅនឹងអង្គុលីលេខនោះ ដែលអាចប្រតិបត្តិការ (Network) វាយចេញជាអក្សរខ្មែរបាន។

បន្ទាប់ពីបានបង្កើតអង្គុលីលេខអក្សរខ្មែរ នៅឆ្នាំ១៩៥២ លោកបានត្រឡប់មកកម្ពុជាវិញ ហើយទទួលមុខនាទីជាសាស្ត្រាចារ្យនៅវិទ្យាល័យស៊ីសុវត្ថិនៅក្រុងភ្នំពេញ ពីឆ្នាំ១៩៥២ដល់១៩៥៨។ លោកជាអគ្គលេខាធិការរងនៃ «គណបក្សប្រជាធិបតេយ្យ» នៅពេលបោះឆ្នោតនីតិបញ្ញត្តិសកល នៅ ឆ្នាំ១៩៥៥ បន្ទាប់ពីការគ្រោងទុកដោយសន្ធិសញ្ញាក្រុងហ្សឺណែវ នៅក្នុងឆ្នាំ១៩៥៤។ លោកបានប្រឆាំង ដោយចេញមុខនឹងរាជបល្ល័ង្ក ជាពិសេសគឺប្រឆាំងផ្ទាល់នឹងសម្តេច នរោត្តម សីហនុ ដែលជាស្ថាបនិកនៃ «គណបក្សសង្គមរាស្ត្រនិយម»។បន្ទាប់ពីបរាជ័យនៃគណបក្សប្រជាធិបតេយ្យរដ្ឋាភិបាលបានចាប់លោកដាក់គុក នៅថ្ងៃទី១៣ ខែកញ្ញា ដល់ថ្ងៃទី១០ ខែតុលា ១៩៥៥។ នៅឆ្នាំ១៩៥៨ លោកមានតួនាទីជាប្រធានគណៈកម្មការពិនិត្យសៀវភៅអក្សរសាស្ត្រខ្មែរនៅមធ្យមសិក្សា។ ពីឆ្នាំ១៩៥៨ ដល់១៩៦២ លោកមានតំណែងជាព្រឹទ្ធបុរសមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ និងជាចាងហ្វាងវិទ្យាស្ថានជាតិគរុកោសល្យ (១៩៥៨-១៩៦០) ហើយលោកបានទៅបង្រៀនអក្សរសាស្ត្រខ្មែរ វប្បធម៌ អរិយធម៌ខ្មែរ នៅមហាវិទ្យល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ ហើយ និងពុទ្ធិកសកលវិទ្យាល័យភ្នំពេញ រហូតដល់

ឆ្នាំ១៩៦៨។ នៅពាក់កណ្តាលឆ្នាំ១៩៦៨ រាជរដ្ឋាភិបាលបានបញ្ឈប់លោកឱ្យលែងបង្រៀន ហើយបានឱ្យភ្នាក់ងារឃ្លាំមើលគេហដ្ឋានលោកទៀតដោយលោកជាប់ចោទថាជាអ្នកបំបះបំបោរនិស្សិតនិងសិស្សនានាឱ្យធ្វើសកម្មភាពប្រឆាំងនឹងរាជរដ្ឋាភិបាលជំនាន់នោះ។ អាជ្ញាធរជំនាន់នោះបានឆែករុករកនៅផ្ទះសាស្ត្រាចារ្យរូបនេះ ឃើញមានសៀវភៅលទ្ធិកុំមុយនីស្ត ម៉ៅ និង ទស្សនាវដ្តី ប្រទេសចិន... នៅក្នុងបណ្ណាល័យផ្ទាល់របស់លោក ជាហេតុនាំឱ្យអាជ្ញាធរក្រសួងសន្តិសុខ ចាប់លោកឃុំ នៅរាជបណ្ឌិត្យសភានគរបាលដោយចោទថាជាពួកកុំមុយនីស្តនិយមបានបំបះបំបោរនិស្សិត និងប្រជាជនប្រឆាំងនឹងរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម។

បន្ទាប់ពីសភាពការណ៍នយោបាយ នៅឆ្នាំ១៩៧០ ដែលធ្វើឡើងដោយឧត្តមសេនីយ៍លន់នល់ ប្រទេសកម្ពុជាបានក្លាយជាសាធារណរដ្ឋខ្មែរ រដ្ឋាភិបាលថ្មីបានផ្តល់នីតិសម្បទាឱ្យលោកវិញ ហើយបានបង្កើត « វិទ្យាស្ថានខ្មែរ-មន » ដោយតែងតាំងលោកជាមេដឹកនាំស្ថាប័ននេះក្នុងគោលបំណងលើកតម្កើងវប្បធម៌ខ្មែរ-មនឱ្យខ្ពង់ខ្ពស់ ដើម្បីឱ្យជនជាតិខ្មែរមានមោទនភាពជាខ្មែរ និងបង្រួបបង្រួមខ្មែរជាទូទៅ នៅជុំវិញកេរមត៌កវប្បធម៌នេះ។ លោកបានធ្វើនិក្ខេបបទមួយដែលការពារនៅសកលវិទ្យាល័យស៊កបោន (Sorbonne) ប្រទេសបារាំងនៅឆ្នាំ១៩៧១មានចំណងជើងថា « ការស្រាវ ជ្រាវរកឫសគល់មួយនៃ វប្បធម៌ខ្មែរ» (Recherche d´un fond culturel khmer)។

ក្រោយមកលោកបានទទួលតំណែងជាភូឈួយប្រតិភូអចិន្ត្រៃយ៍នៅអង្គការយូណេស្កូ (Unesco) ក្នុងក្រុងប៉ារីសនៅឆ្នាំ១៩៧១។ហើយបន្ទាប់មកទៀតមានតួនាទីជាភារធារីនៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែរប្រចាំប្រទេសបារាំង ពីខែតុលា១៩៧៤ដល់ខែមេសា ១៩៧៥។ លោកបានរស់នៅ ម៉ុងម៉ូរ៉ង់ស៊ី (Mont – morency) នាជាយក្រុងប៉ារីស។ ចំណែកភរិយារបស់លោកបានទទួលមរណភាព នៅឆ្នាំ២០០៣។ លោក កេង វ៉ាន់សាក់ បានចូលជាសមាជិកសមាគមអ្នកនិពន្ធខ្មែរ ថ្ងៃទី ២៩ មករា ១៩៥៨។ លោកបានទទួលមរណភាពនៅថ្ងៃទី១៨ ធ្នូ ២០០៨ នៅទីក្រុងប៉ារីស ប្រទេសបារាំង។

ស្នាដៃរបស់លោកមាន៖

-ចិត្តក្រមុំ (កំណាព្យ ១៩៥៤)

-គុកកាមកិលេស (កំណាព្យ ១៩៥៦)

-ម៉ាស៊ីនអង្គុលីលេខខ្មែរ

-ទ្រឹស្តីអំពីអង្គុលីលេខខ្មែរ

-មូលភាពនៃការបង្កើតពាក្យថ្មីៈ ទ្រឹស្តី (វេយ្យាករណ៍ និង និរុត្តិវិទ្យា) ភ្នំពេញ ១៩៦៤។

មគ្គុទេសក៍វប្បធម៌ទូទៅ
បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## កើតជាមនុស្សនេះ (ភាគគតិ)

កើតជាមនុស្សនេះ បញ្ហាច្រើនម៉្លេះ ចោទជាប់គ្មានឃ្លាត
ដោះមួយរួចទៅ នៅសល់ដប់ទៀត កើតឡើងព្រោងព្រាត
ស្រាយមិនចេះអស់។

មានរឿងក្រពះ ចោទធ្ងន់ពេកណាស់ ត្រូវតែប្រឹងដោះ
ស្រាយចេញឱ្យរួច មុនគេបង្អស់ ទើបរួចរណ្ដោះ
ពីទុក្ខធំបាន។

ប៉ុន្តែមនុស្សនេះ ចិត្តមិនដែលចេះ ស្កប់ត្រឹមបាត់ឃ្លាន
វានៅបញ្ហា លោភលន់ធ្វើមាន ប្រមូលធនធាន
មកគរឱ្យស្កុក។

មានរឿងចង់ថ្កើង កេរ្តិ៍ឈ្មោះលេចឡើង លាន់ឮពេញស្រុក
ចង់ឱ្យគេស្គាល់ មានមាត់មានមុខ ចង់រក្សាទុក
កេរ្តិ៍ឈ្មោះយូរយារ។

មានរឿងកំហូច រប៉ិលរប៉ូច ចង់ផ្គាប់តណ្ហា
ដោយសង្គមមនុស្ស បណ្ដុះប្រាថ្នា ឱ្យមនុស្សត្រូវការ
មិនដែលចេះស្កប់។

មានអ្វីៗទៀត ចិត្តចេះតែឆ្លៀត ចង់បានមិនចប់
បង្កើតជាទុក្ខ គ្មានបានសុខស្ងប់ គ្មានទីបញ្ចប់
ព្រោះកើតជាមនុស្ស។...

កើតជាមនុស្សនេះ - គយ សារុន

## ទុក្ខសោកព្រាត់សារិកា (ពាក្យ៧)

«... មើលដងជ្រលងព្រៃស្រងាត់ ដូចបងព្រាត់បាត់ពៅពិសី
សុក្រំៗចិត្តប្រពន្ធប្ដី នួនស្រីដូចស្រីស្រស់ឆោមឆាយ។
មើលភ្នំធំធេងវែងរឮក មើលទឹករលករលាមសាយ
មើលដីៗដុះវែងអន្លាយ មើលមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្នេហ៍។...»

ល្បើកសេកសារិកា - កវីយោធានរិន្ទ វ៉ាន់ - ១៩១០

## ពិតជាថ្លើមពាសមេឃ !

ក្រោយពីរើសបានគូគាប់ប្រចាំជីវិតគឺនាងសួស្តី ធនញ្ជ័យគ្មានសល់ទ្រព្យអ្វីជាដុំកំភួនទេ គាត់ក៏នឹកឃើញវិធីមួយ ដើម្បីបានប្រាក់ចាយវាយកំដជីវិតគ្រួសារគាត់ នោះគឺល្បែងភ្នាល់។

ធនញ្ជ័យ : អស់លោកមន្ត្រីទាំងអស់ ជឿថាខ្ញុំហ៊ានប្រើស្តេចទេ ?

មន្ត្រី : វាមិនខ្មេះទេអាជ័យអើយ! ឯងពិតជាថ្លើមពាសមេឃមែន! ឯងខ្ជិលដកដង្ហើមហើយឬ ?

ធនញ្ជ័យ : ប្រសិនបើខ្ញុំចាញ់ស្រេចលើព្រះករុណាដាក់ទោសទណ្ឌខ្ញុំចុះ តែបើខ្ញុំឈ្នះវិញ អស់លោកហ៊ានឱ្យអីខ្ញុំ ?

មន្ត្រី : យើងឱ្យប្រាក់ឯងក្នុងម្នាក់ៗ ៥០ គហបណៈ ។ ពួកមន្ត្រីវាសម្ទីម្នាយករឿងនេះទៅទូលស្តេច ដើម្បីឱ្យព្រះអង្គខ្ញាល់នឹងធនញ្ជ័យ ដែលហ៊ានប្រមាថព្រះចេស្តា និងឱ្យស្តេចកាត់ទោសប្រហារជីវិត ធនញ្ជ័យចោល ។ ស្តេចឱ្យហៅធនញ្ជ័យមកចូលគាល់ ។

ស្តេច : មើល៍ ! អាជ័យឯងបាននិយាយប្រាប់លោកមន្ត្រីថា ឯងហ៊ានប្រើអញមែនឬទេ ?

ធនញ្ជ័យ : កុរណាថ្លៃវិសេស ! ទូលព្រះបង្គំជាខ្ញុំបាននិយាយ អញ្ចឹងមែន ក្រាបទូល ។

ស្តេច : ឥឡូវចូរឯងប្រើអញមកចុះ ?

ធនញ្ជ័យ : ទាល់តែព្រះអង្គបែរព្រះភក្ត្រទៅខាងស្តាំសិន ទើបទូលបង្គំហ៊ានប្រើក្រាបទូល ។

ស្តេច : ហ៎ក! ឥឡូវអញបែរទៅស្តាំរួចហើយ ចាំអីទៀតក៏មិនប្រើអញមក!

ធនញ្ជ័យ : ក្រាបទូលព្រះអង្គ! បានប្រើរួចហើយគឺបែរព្រះភក្ត្រទៅខាងស្តាំហ្នឹងហើយ ព្រះករុណាថ្លៃវិសេស !

ស្តេច : !!!???

ធនញ្ជ័យញញឹមចាបលាតត្រដាងកន្សែងដើរប្រមូលប្រាក់ពីអស់លោកមន្ត្រីដែលកំពុងគ្រវីក្បាលដូចគោស្រាំងទិច ។

## អ្នកតាទឹក អ្នកតាភ្នំ (ទេវកថា)

កាលពីព្រេងនាយ មានយាយចាស់តាចាស់ពីរនាក់ប្រពន្ធប្តីមានកូនស្រីមួយ ប្រកបដោយរូបឆោមលោមពណ៌ល្អជាទីបំផុត។ ថ្ងៃមួយមានអ្នកតាពីរនាក់ មួយនៅលើភ្នំ មួយនៅក្នុងទឹក បានចូលស្តីដណ្តឹងកូនក្រមុំយាយតាមកធ្វើជាប្រពន្ធ។ យាយតាបានមានប្រសាសន៍ថា៖ «បើអ្នកណាមួយលើកបណ្ណាការមកដល់មុនគេ យើងនឹងលើកកូនស្រីយើងឱ្យធ្វើជាភរិយា»។អ្នកតាភ្នំបាននាំបណ្ណាការទៅជូនយាយតាមកដល់មុនបានទទួលកូនស្រីយាយតានោះ ជាភរិយា ហើយក៏បាននាំប្រពន្ធទៅនៅលើកំពូលភ្នំ។ ថ្លែងពីអ្នកតាទឹកបាននាំភ័ស្តុភារបណ្ណាការមកដែរតែមកដល់ក្រោយមិនបានកូនស្រីយាយតាក៏នឹកខឹងខ្លាំងណាស់បង្កើតបានជាទឹកជំនន់ជន់ឡើងឱ្យលិចគូស្វាមីភរិយាថ្មីដើម្បីផ្តាញ់ផ្តាលសងសឹកគូប្រជែងរបស់ខ្លួនគឺអ្នកតាភ្នំ។អ្នកតាភ្នំពីរនាក់ប្តីប្រពន្ធបបួលគ្នាលើកដីធ្វើជាទំនប់ ទប់ទឹកកុំឱ្យជន់លិចលង់បាន។ អ្នកតាទឹកអស់ឫទ្ធិចុះចាញ់ក៏ដកថយខ្លួនទៅវិញទៅ។

ចំណាំ : គេអាចបកស្រាយថាបាតុភូតទឹកជំនន់ បណ្តាលមកពីកំហឹងគ្រេវគ្រោធដ៏ខ្លាំងក្លារបស់អ្នកតាទឹក វិធានការសមស្របយកមកទប់ទល់នឹងទឹកជំនន់គឺទំនប់ទឹក។ ប៉ុន្តែប្រសិនបើបកស្រាយតាមលក្ខណៈសង្គមការណ៍វិញ ជ័យជំនះរបស់អ្នកតាភ្នំលើអ្នកតាទឹក គឺជាការទទួលយករបបមាតាធិបតេយ្យក្នុងសហគមខ្មែរដើម បន្ទាប់ពីរបបតួតិមនិយមធ្លាក់ចុះទន់ខ្សោយ ។



ប្រាសាទភ្នំដា
ឋិតនៅភូមិព្រៃកតាផ ឃុំគោកធ្លក ស្រុកអង្គរបុរី ខេត្តតាកែវ

